RAOUL WALLENBERG INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW

កម្រងការជកស្រង់យុត្តិសាស្ត្រតុលាការអន្តរជាតិ និងតំបន់ ស្តីពី សិទ្ធិទទួលបានការសម្រេចជាស្ថាពរ និងឆាប់រហ័សក្នុង សំណុំរឿង គោលការណ៍ចិមតិសង្ឆ័យនឹងបានជាប្រយោជន៍ ដល់ជនជាប់ចោទ និងគោលការណ៍ផ្តល់ជាប្រយោជន៍ដល់ ជនជាប់ចោទ (favor rei)

ចងក្រង និងកែសម្រួលដោយ បណ្ឌិត ហស ឡ៉ា និងក្រុមការងារ

ចោះពុម្ពផ្សាយ ឆ្នាំ២០២៤

RAOUL WALLENBERG INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW

ការចងក្រងនេះ ត្រូវបានរៀបចំដោយវិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺក ដោយមានការគាំទ្រផ្នែកហិរញ្ញវត្ថុពីការិយាល័យស្ថានទូតស៊ុយអែតប្រចាំទីក្រុងភ្នំពេញ។

គោលបំណងនៃការចងក្រងនេះ គឺដើម្បីបង្កើនឯកសារពាក់ព័ន្ធនឹងសិទ្ធិស្តីពីការជំនុំជម្រះ ដោយយុត្តិធម៌ជាភាសាខ្មែរឱ្យកាន់តែទូលំទូលាយ ជាជំនួយដល់ការសិក្សាស្រាវជ្រាវរបស់និស្សិតអ្នកអនុវត្តច្បាប់និងអ្នកអានទូទៅ។
វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺកសង្ឃឹមថាឯកសារទាំងនេះនឹងមានប្រយោជន៍ច្រើនក្នុងការរួមចំណែកដល់ ការស្រាវជ្រាវ និងការអប់រំសិទ្ធិមនុស្សនៅកម្ពុជា។

ភ្នំពេញ, ខែឧសភា ឆ្នាំ២០២៤

ការបដិសេធ៖ មតិដែលបានបង្ហាញនៅក្នុងការឯកសារនេះ គឺជាទស្សនៈតុលាការថ្នាក់អន្តរជាតិ និងតំបន់ដោយផ្ទាល់ដែលបានដកស្រង់ ពីសំណុំរឿងជាក់លាក់ និងមិនបានឆ្លុះបញ្ចាំងពីទស្សនៈរបស់វិទ្យាស្ថានរ៉ាអ៊ុលវ៉ាលេនប៊ឺក ឬការិយាល័យស្ថានទូតស៊ុយអែតប្រចាំទីក្រុងភ្នំពេញនោះទេ។

ស៊ុយអែត Sverige

មាតិកាសង្ខេប

ក. សិទ្ធិទទួលបានការសម្រេចជាស្ថាពរ និងយុត្តិសាស្ត្រក្រោយពេលរឿងក្តី Marini តទល់នឹង Albania។

ខ. សិទ្ធិទទួលបានការជំនុំជម្រះ “ដោយគ្មានការពន្យារពេលមិនសមហេតុផល” នៅក្នុងច្បាប់អន្តរជាតិ។

គ. គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ និងគោលការណ៍ផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ។

ឃ. ករណីនៃការជាប់គាំងតុលាការ និងវិធីសាស្ត្រក្នុងការដោះស្រាយនៅតុលាការ និងអង្គជំនុំជម្រះអន្តរជាតិដទៃទៀត។

ង. ការបិទបញ្ចប់ ឬការផ្អាកជាអចិន្ត្រៃយ៍ចំពោះកិច្ចដំណើរការនីតិវិធីដោយសារតែភាពមិនប្រាកដប្រជា ផ្នែកនីតិវិធី។

មាតិកាលម្អិត

ក. សិទ្ធិទទួលបានការសម្រេចជាស្ថាពរលើរឿងក្តី..... 1

សិទ្ធិដែលធានាដោយមាត្រា៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស 1

រឿងក្តី Marini តទល់នឹង Albania..... 3

តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី ដែលគាំទ្រសិទ្ធិទទួលបានការសម្រេចជាស្ថាពរ ក្រោយរឿងក្តី Marini..... 4

តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីដែលដកស្រង់ដោយផ្ទាល់នូវរឿងក្តី Marini តទល់នឹង Albania 8

តុលាការសិទ្ធិមនុស្សអឺរ៉ុប 14

រឿងក្តីបញ្ជូនដែលបានដកស្រង់ដោយផ្ទាល់នូវរឿងក្តី Marini តទល់នឹង Albania 14

ការមិនអាចសម្រេចលើបញ្ហា ដោយសារតែតុលាការបដិសេធយុត្តាធិការ..... 17

ទំនាក់ទំនងរវាងសិទ្ធិទទួលបានការសម្រេចជាស្ថាពរ និងសិទ្ធិទទួលបានការជំនុំជម្រះ “ដោយគ្មានការពន្យារពេលមិនសមស្រប” 20

ខ. សិទ្ធិទទួលបានការជំនុំជម្រះ “ដោយគ្មានការពន្យារពេលមិនសមស្រប” សិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័ស..... 23

គោលដៅនៃសិទ្ធិទទួលបានការជំនុំជម្រះ “ដោយគ្មានការពន្យារពេលមិនសមស្រប” 25
សិទ្ធិតាមលក្ខន្តិក:ព្រហ្មទណ្ឌអន្តរជាតិនីមួយៗ 29
សិទ្ធិតាមក្រមព្រហ្មទណ្ឌកម្ពុជា 30
សិទ្ធិតាមក្រមនីតិវិធីព្រហ្មទណ្ឌបារាំង 31
គោលការណ៍ពាក់ព័ន្ធនានាក្នុងការសម្រេចលើភាពសមស្រប 32
តើពេលវេលាដែលត្រូវធ្វើការពិចារណា ចាប់ផ្តើមនៅពេលណា? . 33
តើពេលវេលាដែលត្រូវធ្វើការពិចារណា បញ្ចប់នៅពេលណា? 37
លក្ខណវិនិច្ឆ័យពាក់ព័ន្ធ ក្នុងការសម្រេចលើភាពសមស្រប 39
កម្រិតនៃយុត្តាធិការ គឺជាកត្តាពាក់ព័ន្ធមួយផ្សេងទៀត 76
តុលាការសិទ្ធិមនុស្សអឺរ៉ុប ឧទាហរណ៍ជាច្រើន នៃការផុតពេលវេលាដែលសមស្រប (មួយកម្រិតយុត្តាធិការ) 79
តុលាការសិទ្ធិមនុស្សអឺរ៉ុប ឧទាហរណ៍ជាច្រើន នៃការផុតពេលវេលាដែលសមស្រប (ពីរកម្រិតយុត្តាធិការ) 81
តុលាការសិទ្ធិមនុស្សអឺរ៉ុប ឧទាហរណ៍ជាច្រើន នៃការមិនទាន់ផុតពេលវេលាដែលសមស្រប (ពីរកម្រិតយុត្តាធិការ) 83
តុលាការចំពោះកិច្ច ឧទាហរណ៍ជាច្រើននៃការមិនទាន់ផុតពេលវេលាដែលសមស្រប 85

សេចក្តីប្រកាស និងវិធានការរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងសិទ្ធិ 86

គ. គោលការណ៍ការជំនុំជម្រះប្រកបដោយយុត្តិធម៌ គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ និងគោលការណ៍ផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ 90

និយមន័យ និងវិសាលភាព 90

យុត្តិសាស្ត្រ ដែលប្រឆាំងគ្នា លើវិសាលភាពនៃគោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ នៅតុលាការចំពោះកិច្ចនានា 92

តុលាការព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍អនុវត្តចំពោះទាំង បញ្ហាអង្គហេតុ និងបញ្ហាអង្គច្បាប់ 98

តុលាការព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍អនុវត្តនៅគ្រប់ដំណាក់កាល 100

អ.វ.ត.ក វិសាលភាពនៃគោលការណ៍ ផ្អែកលើអង្គជំនុំជម្រះតុលាការកំពូល 100

អ.វ.ត.ក វិសាលភាពនៃគោលការណ៍ ផ្អែកលើអង្គបុរេជំនុំជម្រះ 104

គោលការណ៍ផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ ពាក់ព័ន្ធនានាសម្រាប់ដោះស្រាយបញ្ហាអង្គច្បាប់ 106

គោលការណ៍ផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទសម្រាប់ដោះស្រាយភាពខ្វះចន្លោះនៃច្បាប់ 108

ចំណងទាក់ទងជាប្រវត្តិសាស្ត្រ ជាមួយនឹងការដោះស្រាយភាពជាប់គាំងផ្នែកនីតិវិធី..... 109

ឃ. ករណីនៃភាពជាប់គាំងតុលាការ នៅតុលាការនិងអង្គជំនុំជម្រះអន្តរជាតិដទៃទៀត 110

សេចក្តីផ្តើម..... 110

តុលាការពិសេសសម្រាប់ប្រទេសលីបង់ 110

អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់ប្រទេសលីបង់ ញត្តិស្តីពី “ឃុត្តាធិការដែលមានស្រាប់”..... 120

តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន..... 122

ករណីនៃការជាប់គាំងតុលាការនៅតុលាការ Nuremberg 124

ង. ការបិទបញ្ចប់ ឬការផ្អាកជាអចិន្ត្រៃយ៍ ចំពោះកិច្ចដំណើរការនីតិវិធី ដោយសារតែភាពមិនច្បាស់ជាប្រជាផ្នែកនីតិវិធី.....125

ក. សិទ្ធិទទួលបានការសម្រេចជាស្ថាពរលើរឿងក្តី

សិទ្ធិដែលធានាដោយមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស

១, តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចនៅក្នុងរឿងក្តីជាច្រើនថា សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលមានចែងក្នុងមាត្រា៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស បានធានានូវ "សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការ"[1] និងសិទ្ធិដែលបុគ្គលម្នាក់ៗទទួលបានការសម្រេចក្តីជាស្ថាពរលើវិវាទដោយតុលាការ[2] ។

២, សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការត្រូវបានធានាទាំងនៅក្នុងកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណីនិងព្រហ្មទណ្ឌ[3]។

---

[1] រឿងក្តី *Tinnelly & Sons Ltd និងអ្នកដទៃទៀត និង McElduff* និងអ្នកដទៃទៀត *តទល់នឹងចក្រភពអង់គ្លេស* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 20390/92 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៩៨ កថាខណ្ឌ ៧២, រឿងក្តី *Golder តទល់នឹង ចក្រភពអង់គ្លេស* (តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការពេញអង្គ ពាក្យសុំលេខ 4451/70 ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ១៩៧៥ កថាខណ្ឌ២៨, កថាខណ្ឌ៣៦)។

[2] រឿងក្តី *Lupeni តទល់នឹង ប្រទេសរ៉ូម៉ានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះតុលាការកំពូល ពាក្យសុំលេខ 76943/11 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៨៦ *Garcia តទល់នឹង ប្រទេសអេស្ប៉ាញ* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 38695/97 ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២000 កថាខណ្ឌ៤៣)។

[3] រឿងក្តី *Deweer តទល់នឹង ប្រទេសប៊ែលហ្សិក* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីពីរ ពាក្យសុំលេខ 6903/75 ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៨0 កថាខណ្ឌ៤៩)។

៣, សិទ្ធិនេះត្រូវបានអនុវត្តនៅក្នុងសេណារីយ៉ូផ្សេងៗគ្នាជាច្រើន។ សិទ្ធិនេះត្រូវបានយកមកអនុវត្តក្នុងករណីដោះស្រាយការផ្អាកកិច្ចដំណើរការនីតិវិធី[4] ករណីពាក់ព័ន្ធនឹងភាពអយុត្តិធម៌[5] ដែលតុលាការមិនបានប្រើប្រាស់យុត្តាធិការរបស់ខ្លួនឱ្យបានពេញលេញ[6]

---

[4] រឿងក្តី *Lupeni តទល់នឹង ប្រទេសរ៉ូម៉ានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះតុលាការកំពូល ពាក្យសុំលេខ 76943/11 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ៨៦)។ រឿងក្តី *Kutic តទល់នឹង ប្រទេសក្រូអាត* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 48778/99 ថ្ងៃទី១ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ២៥ កថាខណ្ឌ៣២)។

[5] រឿងក្តី *Acimovic តទល់នឹង ប្រទេសក្រូអាត* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 61237/00 ថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ៤០–៤២)។ រឿងក្តី *Beneficio តទល់នឹង ប្រទេស San Marino* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីពីរ ពាក្យសុំលេខ 40786/98 ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ២៩ “តុលាការកត់សម្គាល់ថា វិហារសាសនារបស់អ្នកដាក់ពាក្យ អាចប្តឹងទៅតុលាការទាំងអស់នោះបាន ប៉ុន្តែ មិនមានតុលាការណាមួយ បានចេញសេចក្តីសម្រេចថាតើ ខ្លួនមានសិទ្ធិអំណាចដែរ ឬអត់ ក្នុងការប្រគល់ឱ្យវិញ នូវផ្ទៃដីដែលត្រូវបានអសង្ហរិក ប៉ុន្តែមិនបានប្រើប្រាស់នោះ។ តាមមតិរបស់តុលាការ ស្ថានភាពនេះធ្វើឱ្យមានភាពអយុត្តិធម៌ ដែលធ្វើឱ្យប៉ះពាល់ដល់ ផ្នែកសំខាន់បំផុតនៃសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការ របស់វិហារសាសនាអ្នកដាក់ពាក្យ ដូចមានការធានាការពារដោយ មាត្រា ៦(១) នៃអនុសញ្ញា។ ជាលទ្ធផល នេះគឺជាការរំលោភបំពានទៅលើបទប្បញ្ញត្តិនោះ”។

[6] រឿងក្តី *Terra Woningen តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 20641/92 ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៦ កថាខណ្ឌ ៥៣ –៥៥)។ រឿងក្តី *Chevrol តទល់នឹង ប្រទេសបារាំង* តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីពីរ ពាក្យសុំលេខ 49636/99 ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣ កថាខណ្ឌ៥៧–៨៤។ រឿងក្តី *Rotaru តទល់នឹង ប្រទេសរ៉ូម៉ានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះតុលាការ កំពូល ពាក្យសុំលេខ 28341/95 ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០០។

ករណីដែលតុលាការមិនបានសម្រេចលើបញ្ហាមួយតាមអាជ្ញាយុ-កាល[7] និងករណីដែលមានការបដិសេធមិនចេញសេចក្តីសម្រេចស្ថាពរ ដោយសារតែភាពជាប់គាំងតុលាការ[8]។

រឿងក្តី Marini តទល់នឹង Albania

៤, ចំពោះសេណារីយ៉ូចុងក្រោយ នៅក្នុងរឿងក្តី Marini តទល់នឹង Albania (ឆ្នាំ២០០៧) អ្នកដាក់បណ្តឹងបានលើកឡើងថា តាមមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស សិទ្ធិរបស់គាត់ត្រូវបានរំលោភបំពាន ដោយសារតែតុលាការធម្មនុញ្ញ មិនអាចសម្រេចជាស្ថាពរលើបញ្ហាអង្គសេចក្តីនៃវិវាទ ក្រោម ហេតុផលសំឡេងឆ្នោតមិនចុះសម្រុងស្មើគ្នា។ នៅពេលវាយតម្លៃថាតើមានការរំលោភ បំពានដែរឬអត់នោះ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា[9]

> តុលាការសូមរំឭកពីមាត្រា៦ នៃអនុសញ្ញាដែលមិនតម្រូវឱ្យភាគីជាហត្ថលេខី បង្កើតតុលាការឧទ្ធរណ៍ ឬតុលាការកំពូលឡើយ។ ទោះជាយ៉ាងនេះក្តី រដ្ឋដែលបង្កើតតុលាការបែបនេះ ត្រូវបានតម្រូវឱ្យធានាថា បុគ្គលដែលទទួលខុសត្រូវតាមច្បាប់នៅចំពោះ

[7] រឿងក្តី *Ganci តទល់នឹង ប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 41576/98 ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ៣១។

[8] រឿងក្តី *Marini តទល់នឹង ប្រទេសAlbania* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 3738/02 ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ១២០។

[9] ដូចជើងទំព័រខាងលើ។

មុខតុលាការទាំងនេះ ត្រូវទទួលបានការធានាជាសារវ័ន្តដូចមាន ចែងក្នុងមាត្រា៦... ការធានាទាំងអស់នេះរួមមាន សិទ្ធិទទួលបាន ការសម្រេចជាស្ថាពរ លើវិវាទដែលបានដាក់ជូនទៅតុលាការ ដូច ជាក្នុងករណីអ្នកដាក់ បណ្តឹង គឺសេចក្តីសម្រេចលើភាពអាចទទួល យកបាន និង/ ឬបញ្ហាអង្គសេចក្តីនៃបណ្តឹងធម្មនុញ្ញរបស់គាត់។

តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីដែលគាំទ្រសិទ្ធិទទួលបានការសម្រេច ជាស្ថាពរ ក្រោយរឿងក្តី Marini

៥, ចាប់តាំងពីឆ្នាំ២០០៧ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានគាំទ្រជាច្រើន លើកច្រើនសារ ចំពោះគោលការណ៍ដែលថា សិទ្ធិទទួលបានការជំនុំ ជម្រះក្តីប្រកបដោយយុត្តិធម៌តាមមាត្រា ៦(១) រួមបញ្ចូលនូវការ ធានាថា ភាគីនៃកិច្ចដំណើរការនីតិវិធីត្រូវមានសិទ្ធិទទួលបានការ សម្រេចជាស្ថាពរលើជម្លោះពីតុលាការ ដែលស្នើរតែទាំងអស់គឺ ពាក់ព័ន្ធជាមួយនឹងកិច្ចដំណើរការនីតិវិធីរដ្ឋប្បវេណី មិនមែនព្រហ្ម ទណ្ឌទេ។

៦, ជាឧទាហរណ៍ក្នុងរឿងក្តី Lupeni តទល់នឹង Romania (ឆ្នាំ២០១៦) តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា[10]

[10] រឿងក្តី *Lupeni តទល់នឹង ប្រទេសរ៉ូម៉ានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះ តុលាការកំពូល ពាក្យសុំលេខ 76943/11 ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៨៦)។

សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការ ចាំបាច់ត្រូវតែ “ជាក់ស្តែងនិងមានប្រសិទ្ធភាព” ពុំមែនត្រឹមតែជាទ្រឹស្តីឬការស្រមើស្រមៃឡើយ...ការសង្កេតនេះរឹតតែជាការពិតថែមទៀត ជាពិសេសនៅក្នុងការធានាការពារដូចមានចែងក្នុងមាត្រា៦ ដោយផ្អែកលើផ្នែកច្បាស់លាស់ដែលមាននៅក្នុងសង្គមប្រជាធិបតេយ្យនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ...។ ដើម្បីឱ្យសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការ មានប្រសិទ្ធភាព បុគ្គលម្នាក់ៗចាំបាច់ត្រូវមានឱកាសច្បាស់លាស់ និងជាក់ស្តែង ក្នុងការជំទាស់ចំពោះកិច្ចណា មួយដែលជាការជ្រៀតជ្រែកទៅលើសិទ្ធិរបស់ខ្លួន...។ ដូចគ្នានេះដែរ សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការ រួមមានសិទ្ធិចាប់ផ្តើមកិច្ចដំណើរការនីតិវិធី ព្រមទាំងសិទ្ធិទទួលបានការសម្រេចជាស្ថាពរលើជម្លោះដោយតុលាការ (លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)។

៧, តុលាការបានលើកឡើងពីការកត់សម្គាល់ប្រហែលគ្នាក្នុងរឿងក្តីរដ្ឋប្បវេណីនាពេលថ្មីៗនេះ ដូចជា Kabkov តទល់នឹង Russia (ឆ្នាំ២០០៨),[11] Mihaylov តទល់នឹង Bulgaria (ឆ្នាំ២០០៨),[12]

[11] រឿងក្តី *Kabkov តទល់នឹង ប្រទេសរុស្ស៊ី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 12377/03 ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ៤២)។

[12] រឿងក្តី *Mihaylov តទល់នឹង ប្រទេសប៊ុលហ្គារី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីប្រាំ ពាក្យសុំលេខ 17868/07 ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៨ កថាខណ្ឌ៣៨)។

Bulanov តទល់នឹង Ukraine (ឆ្នាំ២០១០),[13] Menshakova តទល់នឹង Ukraine (ឆ្នាំ២០១០),[14] Chuykina តទល់នឹង Ukraine (ឆ្នាំ ២ ០ ១ ១),[15] Muscat តទល់ នឹង Malta (ឆ្នាំ ២ ០ ១ ២),[16] Camovski តទល់ នឹង Croatia (ឆ្នាំ ២ ០ ១ ២),[17] Deguara តទល់នឹង Malta (ឆ្នាំ២០១៣),[18] Perusko តទល់នឹង Croatia (ឆ្នាំ ២ ០ ១ ៣),[19] Perusko តទល់ នឹង Croatia (ឆ្នាំ ២ ០ ១ ៣),[20] Patrinjei តទល់នឹង Romania (ឆ្នាំ ២ ០ ១ ៤),[21]

---

[13] រឿងក្តី *Bulanov តទល់នឹង ប្រទេសអ៊ុយក្រែន* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីប្រាំ ពាក្យសុំលេខ 7714/06 ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១០ កថាខណ្ឌ៣៦)។

[14] រឿងក្តី *Menshakova តទល់នឹង ប្រទេសអ៊ុយក្រែន* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីប្រាំ ពាក្យសុំលេខ 377/02 ថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០ កថាខណ្ឌ៥២)។

[15] រឿងក្តី *Chuykina តទល់នឹង ប្រទេសអ៊ុយក្រែន* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីប្រាំ ពាក្យសុំលេខ 28924/04 ថ្ងៃទី១៣ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ៥០)។

[16] រឿងក្តី *Muscat តទល់នឹង ប្រទេស Malta* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 24197/10 ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ កថាខណ្ឌ៤៥)។

[17] រឿងក្តី *Camovski តទល់នឹង ប្រទេសក្រូអាត* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 38280/10 ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ កថាខណ្ឌ៣៩)។

[18] រឿងក្តី *Deguara តទល់នឹង ប្រទេសMalta* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 14796/11 ថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ៨៨)។

[19] រឿងក្តី *Perusko តទល់នឹង ប្រទេសក្រូអាត* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 36998/09 ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣)។

[20] រឿងក្តី *Perusko តទល់នឹង ប្រទេសក្រូអាត* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 36998/09 ថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៣ កថាខណ្ឌ៤៨)។

Kardos តទល់នឹង Croatia (ឆ្នាំ២០១៦),[22] Leuska តទល់នឹង Esto-nia (ឆ្នាំ ២ ០ ១ ៧),[23] Muic តទល់នឹង Croatia (ឆ្នាំ ២០១៧),[24] Centre for the Development of Analytical Psy-chology តទល់នឹង The Former Yugoslav Republic of Macedonia (ឆ្នាំ ២ ០ ១ ៧),[25] Regner តទល់នឹង The Czech Republic (ឆ្នាំ២០១៧),[26] Tordaj តទល់នឹង Serbia (ឆ្នាំ ២ ០ ១ ៧),[27] Lesciukaitis តទល់នឹង Lithuania (ឆ្នាំ

---

[21] រឿងក្តី *Patrinjei តទល់នឹង ប្រទេសរ៉ូម៉ានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបី ពាក្យសុំលេខ 54950/07 ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ៣៣)។

[22] រឿងក្តី *Kardos តទល់នឹង ប្រទេសក្រូអាត* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីពីរ ពាក្យសុំលេខ 25782/11 ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ៤៨)។

[23] រឿងក្តី *Leuska តទល់នឹង ប្រទេស Estonia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីពីរ ពាក្យសុំលេខ 64734/11 ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៧ កថាខណ្ឌ៦៧)។

[24] រឿងក្តី *Muic តទល់នឹង ប្រទេសក្រូអាត* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីពីរ ពាក្យសុំលេខ 79653/12 ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ៤៤)។

[25] រឿងក្តី *មជ្ឈមណ្ឌលសម្រាប់ការអភិវឌ្ឍន៍ ចិត្តវិទ្យាវិភាគ តទល់នឹង The Former Yugoslav Republic of Macedonia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 29545/10 ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ៤៥)។

[26] រឿងក្តី *Regner តទល់នឹង សាធារណរដ្ឋឆែក* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះតុលាការកំពូល ពាក្យសុំលេខ 35289/11 ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ៣៣)។

[27] រឿងក្តី *Tordaj តទល់នឹង ប្រទេស Serbia* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបី ពាក្យសុំលេខ 19728/08 ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ១៧)។

២០១៧),[28] Kamenova តទល់នឹង Bulgaria (ឆ្នាំ២០១៨),[29] Kristiana តទល់នឹង Lithuania (ឆ្នាំ២០១៨),[30] Brajovic តទល់នឹង Montenegro (ឆ្នាំ២០១៨),[31] Kandarakis តទល់នឹង Greece (ឆ្នាំ២០២០),[32]។

តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីដែលដកស្រង់ដោយផ្ទាល់នូវរឿងក្តី Marini តទល់នឹង Albania

៨, រឿងក្តីជាច្រើននៅចំពោះមុខតុលាការសិទ្ធិមនុស្សអឺរ៉ុប បានដកស្រង់រឿងក្តី Marini តទល់នឹង Albania (ឆ្នាំ២០០៧)។ រឿងក្តីដែលពិភាក្សាខាងក្រោមនេះ ពាក់ព័ន្ធជាមួយអាជ្ញាធរដែលមិនបានចេញសេចក្តីសម្រេចជាស្ថាពរលើជម្លោះ ដូច្នេះហើយជាការរំ

[28] រឿងក្តី *Lesciukaitis តទល់នឹង Lithuania* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 72253/11 ថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ កថាខណ្ឌ៣៧)។

[29] រឿងក្តី *Kamenova តទល់នឹង ប្រទេសប៊ុលហ្គារី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 62784/09 ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៨ កថាខណ្ឌ៤១)។

[30] រឿងក្តី *Kristiana តទល់នឹង ប្រទេស Lithuania* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 36184/13 ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៨ កថាខណ្ឌ១២២)។

[31] រឿងក្តី *Brajovic តទល់នឹង ប្រទេស Montenegro* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីពីរ ពាក្យសុំលេខ 52529/12 ថ្ងៃទី៣0 ខែមករា ឆ្នាំ២០១៨ កថាខណ្ឌ៤៨)។

[32] រឿងក្តី *Kandarakis តទល់នឹង ប្រទេសក្រិក* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 48345/12, 48348/12, 67463/12 ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២0 កថាខណ្ឌ៤៦)។

លោភបំពានទៅលើមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស។

៩, នៅក្នុងរឿងក្តី Avdic និងអ្នកដទៃទៀត តទល់នឹង Bosnia និង Herzegovina (ឆ្នាំ២០១៣) អ្នកដាក់ពាក្យសុំបានលើកឡើងថា សិទ្ធិរបស់ពួកគាត់ក្នុងការទទួលបានការសម្រេចជាស្ថាពរលើវិវាទតាមមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស ត្រូវបានរំលោភបំពានដោយសារតែ តុលាការធម្មនុញ្ញនោះ មិនអាចស្វែងរកសំឡេងភាគច្រើនលើសលប់[33]។ រឿងក្តីចាប់ផ្តើមឡើងដោយអ្នកដាក់បណ្តឹងចំនួន បីរូប ដោយតុលាការសិទ្ធិមនុស្សអឺរ៉ុប បានសម្រេចបញ្ចូលសំណើសុំរបស់ពួកគេរួមគ្នា[34]។

១០, ចំពោះអ្នកដាក់បណ្តឹង ពីរ រូបដំបូង រឿងក្តីនីមួយៗរបស់ពួកគាត់ត្រូវបានបដិសេធចោលនៅដំណាក់កាលបណ្តឹងសាទុក្ខដោយតុលាការធម្មនុញ្ញ Bosnia និង Herzegovina ព្រោះក្រុមប្រឹក្សាជំនុំជម្រះ ដែលរួមមានចៅក្រមជ្រាំបីរូប មិនអាចស្វែងរកសំឡេងភាគច្រើនលើសលប់របស់ចៅក្រមជ្រាំរូបតាមការកំណត់

[33] រឿងក្តី *Avdic* និងអ្នកដទៃទៀត *តទល់នឹង ប្រទេស Bosnia និង Herzegovina* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 28357/11, 31549/11, 39295/11 ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ២០)។

[34] រឿងក្តី *Avdic* និងអ្នកដទៃទៀត *តទល់នឹង ប្រទេស Bosnia និង Herzegovina* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 28357/11, 31549/11, 39295/11 ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ១, កថាខណ្ឌ១៩)។

[35]។ ចំពោះអ្នកដាក់បណ្តឹងទីបី បណ្តឹងសាទុក្ខរបស់គាត់ត្រូវបានច្រានចោល ដោយសារមូលហេតុដូចគ្នា ប៉ុន្តែក្នុងករណីពិសេសរបស់គាត់ ក្រុមប្រឹក្សាជំនុំជម្រះមានចៅក្រមតែប្រាំពីររូប[36]។

១១, រដ្ឋធម្មនុញ្ញនៃប្រទេស Bosnia និង Herzegovina តម្រូវឱ្យមានសមាជិកសរុបប្រាំបីរូប[37]។ វិធាន ៤០(៣) នៃវិធានតុលាការធម្មនុញ្ញចែងថា[38]៖

«ក្នុងករណីលើកលែងពិសេស នៅពេលដែលមានចៅក្រមសរុបតិចជាងប្រាំបួនរូប ចូលរួមក្នុងនីតិវិធីធ្វើការសម្រេចនៅកិច្ចប្រជុំពេញអង្គ... លុះត្រាតែមានចៅក្រមយ៉ាងតិចបំផុតប្រាំរូប បានបោះឆ្នោតដូចគ្នា លើសេចក្តីព្រាងសេចក្តីសម្រេច

---

[35] រឿងក្តី *Avdic* និងអ្នកដទៃទៀត *តទល់នឹង ប្រទេស Bosnia និង Herzegovina* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 28357/11, 31549/11, 39295/11 ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ៦–១២)។

[36] រឿងក្តី *Avdic* និងអ្នកដទៃទៀត *តទល់នឹង ប្រទេស Bosnia និង Herzegovina* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 28357/11, 31549/11, 39295/11 ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣) កថាខណ្ឌ១៣–១៦)។

[37] រឿងក្តី *Avdic* និងអ្នកដទៃទៀត *តទល់នឹង ប្រទេស Bosnia និង Herzegovina* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 28357/11, 31549/11, 39295/11 ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣) កថាខណ្ឌ១៧)។

[38] រឿងក្តី *Avdic* និងអ្នកដទៃទៀត *តទល់នឹង ប្រទេស Bosnia និង Herzegovina* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 28357/11, 31549/11, 39295/11 ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ១៨)។

លើបណ្តឹងសាទុក្ខ បើមិនដូច្នេះទេ ត្រូវពិចារណាថាសេចក្តីសម្រេចដែលត្រូវធ្វើគឺបដិសេធ(ដោយគូសបញ្ជាក់បន្ថែម)។»

១២, រដ្ឋាភិបាលបានជំទាស់ថា បន្ទុកការងារដែលកាន់តែកើនឡើងរបស់តុលាការធម្មនុញ្ញ តម្រូវឱ្យមានការប្រើវិធាន ៤០(៣) ដែលអនុញ្ញាតឱ្យតុលាការដំណើរការកាន់តែមានប្រសិទ្ធភាព ជាងមុនលើបណ្តឹងសាទុក្ខ[39]។ ផ្ទុយមកវិញ អ្នកដាក់ពាក្យបានប្តឹងថា ការច្រានចោលបណ្តឹងសាទុក្ខ ស្របតាមរដ្ឋធម្មនុញ្ញរបស់ពួកគេ គឺជាការបដិសេធចំពោះពួកគេចំពោះ "សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការ ដែលផ្ទុយនឹងមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស[40]។ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានសម្រេចយល់ស្របតាម[41]។

---

[39] រឿងក្តី *Avdic* និងអ្នកដទៃទៀត *តទល់នឹង ប្រទេស Bosnia និង Herzegovina* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 28357/11, 31549/11, 39295/11 ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ៣០)។

[40] រឿងក្តី *Avdic* និងអ្នកដទៃទៀត*តទល់នឹង ប្រទេស Bosnia និង Herzegovina* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 28357/11, 31549/11, 39295/11 ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ២០)។

[41] រឿងក្តី *Avdic* និងអ្នកដទៃទៀត *តទល់នឹង ប្រទេស Bosnia និង Herzegovina* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 28357/11, 31549/11, 39295/11 ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៣) កថាខណ្ឌ៣៧)។

តុលាការច្រានចោលការស្នើឡើងរបស់រដ្ឋាភិបាលដែលថារឿង ក្តីបច្ចុប្បន្ន គួរតែខុសប្លែកពីរឿងក្តី Marini។ ទោះបីជាសេចក្តីសម្រេចដែលរងការជំទាស់ គឺសេចក្តីសម្រេចស្ថាពរក្តី តែសេចក្តីសម្រេចនេះមិនពាក់ព័ន្ធ “ការសម្រេច” ស្ថាពរនៃសិទ្ធិ និងកាតព្វកិច្ចរដ្ឋប្បវេណី របស់អ្នកដាក់ពាក្យសុំឡើយ។ ទោះបីជាតុលាការធម្មនុញ្ញធ្វើការសម្រេចជាផ្លូវការលើបណ្តឹងសាទុក្ខរបស់អ្នកដាក់ពាក្យសុំក្តីតែតុលា ការបានបដិសេធដោយប្រសិទ្ធភាព មិនសម្រេចលើភាពអាចទទួល យកបាន និង/ឬអង្គសេចក្តីឡើយ។ សេចក្តីសម្រេចដែលរងការជំ ទាស់មានសំអាងហេតុទាំងគាំទ្រ និងប្រឆាំងចំពោះការសម្រេចលើការរំលោភបំពានហើយសំអាងហេតុតែមួយពីមូលហេតុ ដែលបណ្តឹងសាទុក្ខរបស់អ្នកដាក់ពាក្យសុំ ត្រូវបានបដិសេធចោល គឺ ការដែលតុលាការមិនអាចស្វែងរកសំឡេង ភាគច្រើនលើសលប់ លើបញ្ហាណាមួយដែលអាចសម្រេចអំពីសិទ្ធិ និងកាតព្វកិច្ចរដ្ឋប្បវេណី របស់អ្នកដាក់ពាក្យសុំ។ និយាយម្យ៉ាងទៀត មិនមានសំឡេងភាគច្រើនលើសលប់សម្រាប់ការទទួលយក ឬបដិសេធបណ្តឹងសាទុក្ខរបស់ពួកគេ។ ក្នុងករណីដែលមិនមាន “ការសម្រេច” ពិតប្រាកដលើសិទ្ធិ និងកាតព្វកិច្ចរដ្ឋប្បវេណី សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមិនមែនមានតែទ្រឹស្តីនោះទេ (សូមមើលរឿងក្តី Marini) (ដោយគូសបញ្ជាក់បន្ថែម)

១៣, ក្នុងរឿងក្តី Pasquini តទល់នឹង San Marino (ឆ្នាំ២០១៩) អ្នកដាក់ពាក្យបានប្តឹងថា តុលាការជំនុំជម្រះបណ្តឹងសាទុក្ខរបស់គាត់ បង្កើតឡើងដោយខុសច្បាប់ ជាពិសេសសេចក្តីសម្រេចរបស់តុលាការនោះ គួរតែធ្វើឡើងដោយសំឡេងភាគច្រើនលើសលប់ ប៉ុន្តែក្នុងរឿងក្តីរបស់គាត់ ក្រុមប្រឹក្សាជំនុំជម្រះមានតែចៅក្រមពីររូប ដូច្នេះហើយទើបសេចក្តីសម្រេចដោយសំឡេងភាគច្រើនលើសលប់ មិនអាចធ្វើទៅបាន[42]។

១៤, គួរឱ្យចាប់អារម្មណ៍នោះតុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា មិនមានការរំលោភបំពានឡើយ ដោយសម្រេចថា រូបមន្តបង្កើត ដោយមានចៅក្រមពីររូប មិនមានការហាមឃាត់ច្បាស់លាស់ឡើយ តាមច្បាប់ជាតិ[43]។ តុលាការបានសម្រេចថា[44]

«ទោះបីជាក្នុងកាលៈទេសៈមួយចំនួន រូបមន្តបង្កើតចៅក្រមដែលមិនអាចឈានដល់សំឡេងភាគច្រើនលើសលប់ អាចបណ្តាលឱ្យមានបញ្ហាចំពោះការទទួលបានការជំនុំជម្រះដោយ

---

[42] រឿងក្តី *Pasquini តទល់នឹង ប្រទេស San Marino* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 50956/16 ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩) កថាខណ្ឌ៩៥–៩៧)។

[43] រឿងក្តី *Pasquini តទល់នឹង ប្រទេស San Marino* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 50956/16ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩) កថាខណ្ឌ១០៧)។

[44] រឿងក្តី *Pasquini តទល់នឹង ប្រទេស San Marino* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 50956/16ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩) កថាខណ្ឌ១០៨)។

តុលាការក្តី ដូចក្នុងករណីដែលចំណុចនេះទាំងមានការមិនអាច ធ្វើការសម្រេច បាន (សូមមើលរឿងក្តី Marini តទល់នឹង Albania no. 3738/02, §§ 118-22 ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ ២០០៧) នៅក្នុងកាលៈទេសៈនៃរឿងក្តីបច្ចុប្បន្ន ការដែលថា មានការសម្រេចជាឯកច្ឆ័ន្ទ មិនបានរំលោភបំពានដល់វិធាន សំឡេងភាគច្រើនលើសលប់ឡើយ ហើយក៏មិនបណ្តាល ឱ្យមានវិសមិត ភាពជាមួយច្បាប់ជាតិដែរ។»

តុលាការសិទ្ធិមនុស្សអឺរ៉ុបរឿងក្តីបញ្ជូនដែលបានដកស្រង់ដោយផ្ទាល់នូវ រឿងក្តី Marini តទល់នឹង Albania

១៥, រឿងក្តីខាងក្រោមសុទ្ធតែពាក់ព័ន្ធនឹង “រឿងក្តីដែលត្រូវបញ្ជូន” ដែលជាបណ្តឹងតវ៉ា ក្រោមការត្រួតពិនិត្យរបស់អង្គជំនុំជម្រះ ដែលមានថៅក្រមជ្រាំពីររូប ហើយត្រូវបានចាត់ទុកថាអាចទទួល យកបានជាដំណាក់កាលបឋម ប៉ុន្តែមុនពេលសម្រេចលើអង្គ សេចក្តី អង្គជំនុំជម្រះនឹង “បញ្ជូន” រឿង ក្តីនេះទៅរដ្ឋាភិបាល ពាក់ព័ន្ធនីមួយៗ ដោយជូនដំណឹងដល់ពួកគេអំពី អត្ថិភាពនៃ បណ្តឹងតវ៉ាហើយអនុញ្ញាតឱ្យរដ្ឋាភិបាលដាក់ការសង្កេតរបស់ ខ្លួនលើបញ្ហាដែលជាជម្លោះនេះ។ ក្នុងរឿងក្តីមួយចំនួនខាងក្រោម មិនមានការអនុវត្តកិច្ចដំណើរការនីតិវិធីបន្ថែមឡើយ បន្ទាប់ពី បាន "បញ្ជូន"។

១៦, នៅក្នុងរឿងក្តីនីមួយៗខាងក្រោម អ្នកដាក់ពាក្យនីមួយៗបានប្តឹងថា សិទ្ធិរបស់ពួកគាត់ តាមមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធមនុស្សត្រូវបានរំលោភបំពាន ដោយសារតែពួកគាត់ត្រូវបានបដិសេធសិទ្ធិទទួលបានការសម្រេចជាស្ថាពរលើអង្គសេចក្តីនៃរឿងក្តី។ ក្នុងរឿងក្តីនីមួយៗ ច្បាប់ជាតិបានចែងថា ក្នុងករណីមានសំឡេងឆ្នោតស្មើគ្នា សាលក្រមនឹងត្រូវសម្រេច ប្រឆាំងនឹងភាគីដែលមានកាតព្វកិច្ចបង្ហាញភស្តុតាង។

១៧, នៅក្នុងរឿងក្តីបញ្ជូន Prodhim តទល់នឹង Veshje No. 2 តទល់នឹង Albania (ឆ្នាំ២០១៥) ក្រុមអ្នកដាក់បណ្តឹង[45]ត្រូវបានជូនដំណឹងថា តុលាការធម្មនុញ្ញ ដែលមានចៅក្រមប្រាំបីរូប ក្នុងចំណោមចៅក្រមប្រាំបួនរូប ដូចមានចែងក្នុងច្បាប់ ស្តីពីការរៀប ចំនិងការប្រព្រឹត្តទៅរបស់តុលាការនោះ បានច្រានចោលបណ្តឹងសាទុក្ខរបស់ខ្លួន ដោយសារតែសំឡេងស្មើគ្នា។ សំអាងហេតុរបស់តុលាការមានត្រឹមតែអង្គហេតុ ដែលថា តុលាការមិនអាចឈានដល់សំឡេងភាគច្រើនលើសលប់នៅលើបញ្ហាណាមួយ ដែលបានលើកឡើងក្នុងរឿងក្តីបច្ចុប្បន្ន។ អ្នកដាក់បណ្តឹងត្រូវបានអញ្ជើញឱ្យដាក់ បណ្តឹងតវ៉ាធម្មនុញ្ញថ្មីអនុលោមតាមផ្នែក ៧.៤ នៃច្បាប់ស្តីពីតុលាការធម្មនុញ្ញ (ដោយគូសបញ្ជាក់បន្ថែម)។

[45] រឿងក្តី *Prodhim v Veshje No. 2 តទល់នឹង ប្រទេសAlbania* (តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីបញ្ជូនបន្ត ពាក្យសុំលេខ 34649/14 ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥)។

១៨, ប្រហែលគ្នានេះដែរ នៅក្នុងរឿងក្តីបញ្ជូន Kroi និង Nocka តទល់នឹង Albania (ឆ្នាំ២០១៨) បណ្តឹងសាទុក្ខរបស់អ្នកដាក់ បណ្តឹងត្រូវបានបដិសេធដោយសារតែសំឡេងឆ្នោតស្មើគ្នា នៅក្នុងតុលាការធម្មនុញ្ញ[46]។ អង្គហេតុប្រហែលគ្នាក៏មាននៅក្នុងរឿងក្តីបញ្ជូន Avdyli តទល់នឹង Albania (ឆ្នាំ២០១៥)[47]។

១៩, នៅក្នុងរឿងក្តីបញ្ជូន Loizides តទល់នឹង Cyprus (ឆ្នាំ២០២០) អ្នកដាក់បណ្តឹងបានជំទាស់ចំពោះការដាក់ពិរុទ្ធភាពគាត់ចំពោះបទល្មើសដែលបណ្តាលឱ្យស្លាប់មនុស្ស ដោយសារតែអំពើធ្វេសប្រហែល ហើយផ្តន្ទាទោសដាក់ពន្ធនាគាចំនួនពីរឆ្នាំ[48]។ នៅដំណាក់កាលបណ្តឹងសាទុក្ខ តុលាការកំពូលបានយល់ខុសគ្នា ដោយថៅក្រមប្រាំ មួយរូបសម្រេចតម្កល់ពិរុទ្ធភាពរបស់គាត់ ហើយថៅក្រមប្រាំមួយរូប សម្រេចច្រានចោលពិរុទ្ធភាពគាត់[49]។ អនុលោមតាមច្បាប់ជាតិ តុលាការកំពូលសម្រេចតម្កល់ពិរុទ្ធភាពរបស់គាត់ ហើយច្រានចោល

---

[46] រឿងក្តី *Kroi និង Nocka តទល់នឹង ប្រទេសAlbania* (តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីបញ្ជូនបន្ត ពាក្យសុំលេខ 84056/17 ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨)។

[47] រឿងក្តី *Avdyli តទល់នឹង ប្រទេសAlbania* (តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីបញ្ជូនបន្ត ពាក្យសុំលេខ 5753/15 ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥)។

[48] រឿងក្តី *Loizides តទល់នឹង ប្រទេស Cyprus* (តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីបញ្ជូនបន្ត ពាក្យសុំលេខ 31029/15 ថ្ងៃទី៣0 ខែមេសា ឆ្នាំ២0២0)។

[49] រឿងក្តី *Loizides តទល់នឹង ប្រទេស Cyprus* (តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តីបញ្ជូនបន្ត ពាក្យសុំលេខ 31029/15 ថ្ងៃទី៣0 ខែមេសា ឆ្នាំ២0២0)។

បណ្តឹងសាទុក្ខ។ បើយោងតាម [50]ផ្នែក២៧(២) នៃច្បាប់តុលាការ យុត្តិធម៌លេខ១៤/១៩៦០ ក្នុងករណីដែលតុលាការមានចៅក្រមចំនួន ស្មើគ្នា សាលដីកាត្រូវសម្រេចប្រឆាំងភាគីដែលមានកាតព្វកិច្ចបង្ហាញ ភស្តុតាង (ដោយគូសបញ្ជាក់បន្ថែម)។

២០, ប្រហែលគ្នានេះដែរ នៅក្នុងរឿងក្តីបញ្ជូន Frroku តទល់នឹង Albania (ឆ្នាំ២០១៩) អ្នកដាក់ពាក្យបានជំទាស់ចំពោះពិរុទ្ធភាព របស់គាត់លើបទមនុស្សឃាត និងការផ្តន្ទាទោសដាក់ពន្ធនាគារអស់ មួយជីវិត[51]។ នៅដំណាក់កាលបណ្តឹងសាទុក្ខ តុលាការកំពូល (ក្រុម ប្រឹក្សាជំនុំជម្រះ ដែលមានចៅក្រមបួនរូប) មានការយល់ខុស គ្នាដោយសំឡេងស្មើគ្នា ហើយបើតាមច្បាប់ជាតិ តុលា ការកំពូលត្រូវ តម្កល់សាលក្រមផ្តន្ទាទោសគាត់ ហើយច្រានចោលបណ្តឹងសាទុក្ខ។

ការមិនអាចសម្រេចលើបញ្ហាដោយសារតែតុលាការបដិសេធយុត្តាធិការ

២១, តុលាការសិទ្ធិមនុស្សអឺរ៉ុបបានបញ្ជាក់ថា នៅពេលដែលតុលាការ បដិសេធមិនត្រួតពិនិត្យឡើងវិញលើបញ្ហាអង្គហេតុ និងបញ្ហាអង្ក ច្បាប់ទាំងអស់ ដែលពាក់ព័ន្ធជាមួយនឹងការសម្រេចលើជម្លោះ ដែលជាការដកហូតដោយខ្លួនឯងនូវយុត្តាធិការផ្ទាល់ខ្លួន ពេល

[50] រឿងក្តី *Loizides តទល់នឹង ប្រទេស Cyprus* (តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី បញ្ជូនបន្ត ពាក្យសុំលេខ 31029/1 ថ្ងៃទី៣0 ខែមេសា ឆ្នាំ២0២0)។

[51] រឿងក្តី *Frroku តទល់នឹង ប្រទេសAlbania* (តុលាការសិទ្ធិមនុស្សអឺរ៉ុប រឿងក្តី បញ្ជូនបន្ត ពាក្យសុំលេខ 30658/18 ថ្ងៃទី២៣ ខែមករា ឆ្នាំ២0១៩)។

នោះនឹងមានការរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ អនុលោមតាមមាត្រា ៦(១) [52]។

២២, នៅក្នុងរឿងក្តី Terra Woningen (ឆ្នាំ ១៩៩៦) តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា អ្នកដាក់ពាក្យត្រូវបានបដិសេធនូវសិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការ ព្រោះតុលាការតំបន់ Schiedam “បានដកហូតដោយខ្លួនឯងនូវយុត្តាធិការក្នុងការត្រួតពិនិត្យលើអង្គហេតុ ដែលមានសារសំខាន់សម្រាប់ការសម្រេចលើជម្លោះ”[53]។ តុលាការសិទ្ធិមនុស្សអឺរ៉ុប បានសម្រេចថា[54]

«ការសម្រេចពីសិទ្ធិនិងកាតព្វកិច្ចរដ្ឋប្បវេណីដោយ “តុលាការ” ដើម្បីបំពេញតាមមាត្រា ៦ កថាខណ្ឌ ១ (មាត្រា ៦-១)

---

[52] រឿងក្តី *Terra Woningen តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប Chamber, ពាក្យសុំលេខ 20641/92 ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៦) កថាខណ្ឌ៥៣–៥៥, *Chevrol តទល់នឹង ប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីពីរ ពាក្យសុំលេខ 49636/99 ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣) កថាខណ្ឌ៥៧–កថាខណ្ឌ៨៤, *Rotaru តទល់នឹង ប្រទេសរ៉ូម៉ានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះតុលាការកំពូល ពាក្យសុំលេខ 28341/95 ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០០០)។

[53] រឿងក្តី *Terra Woningen តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 20641/92 ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៦) កថាខណ្ឌ៥៤)។

[54] រឿងក្តី *Terra Woningen តទល់នឹង ប្រទេសហូឡង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 20641/92 ថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៦) កថាខណ្ឌ៥៣, កថាខណ្ឌ៥៥)។

“តុលាការ” ត្រូវបានតម្រូវឱ្យមាន យុត្តាធិការក្នុងការត្រួតពិនិត្យ លើបញ្ហាអង្គហេតុ និងបញ្ហាអង្គច្បាប់ទាំងអស់ ដែលពាក់ព័ន្ធ ជាមួយជម្លោះ នៅចំពោះមុខខ្លួន។... ក្នុងកាលៈទេសៈបែបនេះ ក្រុមអ្នកដាក់ពាក្យមិនអាចត្រូវបានចាត់ទុកថា ទទួលបានការជំនុំ ជម្រះដោយតុលាការ ដែលមានយុត្តាធិការគ្រប់គ្រាន់ ដើម្បី សម្រេចលើរឿងក្តីនៅចំពោះមុខខ្លួនបានឡើយ។ ហេតុដូច្នេះ មានការរំលោភបំពានទៅលើមាត្រា៦ កថាខណ្ឌ១ (ដោយគូស បញ្ជាក់បន្ថែម)។»

២៣, នៅក្នុងរឿងក្តី Chevrol តទល់នឹង France (ឆ្នាំ២០០៣) អ្នក ដាក់ពាក្យសុំបានលើកឡើងថា តុលាការដែលត្រួតពិនិត្យលើបណ្តឹង របស់គាត់ មិនមាន “យុត្តាធិការគ្រប់គ្រាន់ដើម្បីត្រួតពិនិត្យទៅលើ បញ្ហាអង្គហេតុ និងបញ្ហាអង្គច្បាប់ទាំងអស់ ដែលពាក់ព័ន្ធជាមួយ នឹងការសម្រេចលើជម្លោះឡើយ”[55]។ តុលាការបានសម្រេចថា មាន ការរំលោភបំពានទៅលើមាត្រា ៦(១) ដោយសារតែតុលាការបាន យោងទៅលើបញ្ហានៃការបកស្រាយចំពោះអ្នកតំណាងផ្នែកនីតិ ប្រតិបត្តិ[56]។

[55] រឿងក្តី *Chevrol តទល់នឹង ប្រទេសហាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីពីរ ពាក្យសុំលេខ 49636/99 ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣) កថាខណ្ឌ៨៣)។

[56] រឿងក្តី *Chevrol តទល់នឹង ប្រទេសហាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីពីរ ពាក្យសុំលេខ 49636/99 ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០៣) កថាខណ្ឌ៨៤)។

ទំនាក់ទំនងរវាងសិទ្ធិទទួលបានការសម្រេចជាស្ថាពរ និងសិទ្ធិទទួលបានការជំនុំជម្រះ "ដោយគ្មានការពន្យារពេលមិនចាំបាច់"

២៤, នៅក្នុងរឿងក្តី Ganci តទល់នឹង Italy (ឆ្នាំ២០០៣) តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថាមានការរំលោភបំពានទៅលើមាត្រា ៦ (១) ដោយសារតែអាជ្ញាធរមិនបានផ្តល់តាមសំណើអ្នកដាក់ពាក្យសុំ (ពិរុទ្ធជន) ចំនួនបួនដងផ្សេងៗគ្នា នូវសេចក្តីសម្រេចដែលពួកគាត់មានភាតព្វកិច្ចត្រូវចេញក្នុងរយៈពេល ១០ ថ្ងៃ តាមលក្ខខណ្ឌតម្រូវ[57]។ តុលាការបានសម្រេចថា ការមិនចេញសេចក្តីសម្រេចនៅក្នុង រយៈពេលកំណត់នេះ គឺជាការរំលោភបំពានទៅលើសិទ្ធិរបស់អ្នកដាក់ពាក្យ ក្នុងការទទួលបានការជំនុំជម្រះដោយតុលាការ និងសិទ្ធិទទួលបានការសម្រេចជាស្ថាពរលើសិទ្ធិរបស់គាត់។

២៥, នៅក្នុងរឿងក្តីរដ្ឋប្បវេណី Falie តទល់នឹង Romania (ឆ្នាំ ២០១៥) តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចជាច្រើនលើកថា សិទ្ធិទទួលបានការសម្រេចជាស្ថាពរជាប់ទាក់ទងមិនអាចកាត់ផ្តាច់បាន ជាមួយ នឹងការការពារផ្នែកនីតិវិធីដទៃផ្សេងទៀត ដូចជា សិទ្ធិ

[57] រឿងក្តី *Ganci តទល់នឹង ប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 41576/98 ថ្ងៃទី៣0 ខែតុលា ឆ្នាំ២00៣) កថាខណ្ឌ៣១)។

ទទួលបានកិច្ចដំណើរការនីតិវិធីដោយឆាប់រហ័ស ដោយតុលាការបានបញ្ជាក់ថា[58]

តុលាការសូមបញ្ជាក់ថា សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមិនគ្រាន់តែរួមមានសិទ្ធិក្នុងការចាប់ផ្តើមកិច្ចដំណើរការនីតិវិធីប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងសិទ្ធិទទួលបាន "ការសម្រេច" លើវិវាទដោយតុលាការ... សិទ្ធិនោះនឹងមានលក្ខណៈអរូបិយ ប្រសិនបើប្រព័ន្ធគតិយុត្តិជាតិរបស់រដ្ឋហត្ថលេខី អនុញ្ញាតឱ្យបុគ្គលម្នាក់ ដាក់បណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខតុលាការ ដោយមិនមានការធានាថារឿងក្តីត្រូវបានសម្រេចដោយសេចក្តីសម្រេចស្ថាពរក្នុងកិច្ចដំណើរការនីតិវិធីតុលាការ។ ជាការមិនអាចប្រមើលមើលឃើញបានថា មាត្រា៦-១ គួររៀបរាប់លម្អិតអំពីការការពារផ្នែកនីតិវិធី ដែលផ្តល់ជូនដល់គូក្តី គឺកិច្ចដំណើរការនីតិវិធីដែល យុត្តិធម៌ សាធារណៈ និងឆាប់រហ័ស ដោយមិនចាំបាច់ធានាដល់ភាគីនូវសិទ្ធិទទួលបានការសម្រេចជាស្ថាពរលើជម្លោះរដ្ឋប្បវេណីរបស់ខ្លួន (លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)។

២៦, តុលាការបានកត់សម្គាល់ប្រហែលគ្នានៅក្នុងរឿងក្តីកន្លងមក Kutic តទល់នឹង Romania (ឆ្នាំ២០០២)[59] និង Multiplex v Croatia (ឆ្នាំ២០០៣)[60]។

[58] រឿងក្តី *Falie តទល់នឹង ប្រទេសរ៉ូម៉ានី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបី ពាក្យសុំលេខ 23257/04 ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥) កថាខណ្ឌ២២, កថាខណ្ឌ២៤)។

២៧, នៅក្នុងរឿងក្តីដទៃទៀត តុលាការបានសម្រេចថា សិទ្ធិទទួលបានការសម្រេចស្ថាពរ ក៏តម្រូវផងដែរឱ្យ ជូនដំណឹងដល់ភាគីឱ្យបានទៀងទាត់អំពីការវិវត្តនៅក្នុងកិច្ចដំណើរការនីតិវិធី។ ក្នុងរឿងក្តី Dubinskaya v Russia (ឆ្នាំ២០០៦) តុលាការបានសម្រេចថា[61]

---

[59] រឿងក្តី *Kutic តទល់នឹង ប្រទេសក្រូអាត* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 48778/99 ថ្ងៃទី១ ខែមីនា ឆ្នាំ២០០២) កថាខណ្ឌ២៥ មាត្រា ៦(១) នៃអនុសញ្ញាធានានូវសិទ្ធិ ទទួលបានការជំនុំជម្រះដោយតុលាការ សម្រាប់ការសម្រេចលើបណ្តឹងរដ្ឋប្បវេណី។ តុលាការយល់ថា សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការនេះ រួមបញ្ចូលសិទ្ធិចាប់ផ្តើមកិច្ចដំណើរការនីតិវិធី និងសិទ្ធិទទួលបាន "ការសម្រេច" លើបណ្តឹង ដោយតុលាការ។ វានឹងក្លាយជាការបំភាន់ ប្រសិនបើប្រព័ន្ធច្បាប់ជាតិរបស់រដ្ឋហត្ថលេខី អនុញ្ញាតឱ្យបុគ្គលម្នាក់ ដាក់បណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខតុលាការ ប៉ុន្តែ មិនមានការធានាថា រឿងក្តីនោះនឹងត្រូវបានសម្រេចដោយសេចក្តីសម្រេចស្ថាពរ នៅក្នុងកិច្ចដំណើរការនីតិវិធីតុលាការ។ វាជាការមិនអាចយល់បាន សម្រាប់មាត្រា ៦(១) ដែលរៀបរាប់យ៉ាងលម្អិតអំពីការធានាផ្នែកនីតិវិធី សម្រាប់អ្នកដាក់ពាក្យប្តឹង ដែលជាកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ សាធារណៈ និងឆាប់រហ័ស តែមិនមានការធានាចំពោះភាគីថា ជម្លោះរដ្ឋប្បវេណីរបស់ពួកគេ នឹងត្រូវបានសម្រេចជាស្ថាពរនោះ (ដោយគូសបញ្ជាក់បន្ថែម) កថាខណ្ឌ៣២។

[60] រឿងក្តី *Multiplex តទល់នឹង ប្រទេសក្រូអាត* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 58112/00 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៣) កថាខណ្ឌ៤៥)។

[61] រឿងក្តី *Dubinskaya តទល់នឹង ប្រទេសរុស្សី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 4856/03 ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៦) កថាខណ្ឌ៤១ ដកស្រង់រឿងក្តី *Sukhorubchenko តទល់នឹង ប្រទេសរុស្សី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីមួយ ពាក្យសុំលេខ 69315/01 ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៥) កថាខណ្ឌ ៥៣។

«សិទ្ធិរបស់គូក្តីក្នុងការទទួលបានការជំនុំជម្រះដោយតុលាការ នឹងមានលក្ខណៈអរូបិយ ប្រសិនបើគាត់មិនទទួលបានព័ត៌មានអំពីការវិវត្តក្នុងកិច្ចដំណើរការនីតិវិធី និងអំពីសេចក្តីសម្រេចរបស់តុលាការលើបណ្តឹង ជាពិសេសក្នុងករណីដែលសេចក្តីសម្រេចបែបនោះ មានលក្ខណៈជាការរារាំងការត្តួតពិនិត្យបន្ថែមទៀត។ (លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)។»

ខ. សិទ្ធិទទួលបានការជំនុំជម្រះ "ដោយគ្មានការពន្យារពេលមិនចាំបាច់" សិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័ស

២៨, កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌចាំបាច់ត្រូវចាប់ផ្តើម និងបញ្ចប់ដោយមិនមានការពន្យារពេលមិនចាំបាច់ ឬស្ថិតក្នុងពេលវេលាសម ស្រប។ សិទ្ធិនេះមានចែងក្នុងមាត្រា១៤(៣) នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងថា[62]

ក្នុងការសម្រេចលើបទចោទព្រហ្មទណ្ឌប្រឆាំងបុគ្គលម្នាក់ ភាគីទាំងអស់ត្រូវទទួលបានការធានាការពារជាអប្បបរមា ដោយស្មើភាពគ្នាទាំងស្រុង ដូចខាងក្រោម៖

[62] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដាក់សម្រាប់ប្រទេសជាហត្ថលេខីនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៩៦, 999 UNTS 171 *និង* 1057 UNTS 407 (ចូលជាធរមាន ថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧៦)។

(គ) ទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលមិនចាំបាច់ (ដោយគូសបញ្ជាក់បន្ថែម)

២៩, សូមកត់សម្គាល់ថា សិទ្ធិនេះក៏មានចែងនៅក្នុងមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុបស្តីពីសិទ្ធមនុស្ស[63]៖

«សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ក្នុងការសម្រេចលើសិទ្ធិនិងកាតព្វកិច្ចរដ្ឋប្បវេណី ឬបទចោទព្រហ្មទណ្ឌណាមួយ ទៅលើបុគ្គលម្នាក់ ភាគីទាំងអស់ត្រូវទទួលបានការជំនុំជម្រះដោយយុត្តិធម៌ និងជាសាធារណៈ ក្នុងពេលវេលាសមស្របមួយ ដោយតុលាការឯករាជ្យ និងអព្យាក្រិត ដែលបង្កើតឡើងដោយច្បាប់... (ដោយគូសបញ្ជាក់បន្ថែម)។»

៣០, ទោះបីជាប្រើប្រាស់ពាក្យពេចន៍ខុសគ្នាក្តី អាជ្ញាធរជាច្រើនបានកត់សម្គាល់ថា “ការពន្យារពេលដោយមិនសមស្រប” និង “ពេលវេលាសមស្រប” ត្រូវបានប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក[64]។

---

[63] អនុសញ្ញាសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដាក់ឱ្យចុះហត្ថលេខានៅ ថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ១៩៥0, 213 UNTS 221 (ចូលជាធរមាន ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៥៣) ធ្វើវិសោធនកម្មតាមរយៈ ពិធីសារលេខ ១៦ ទៅជាអនុសញ្ញាសម្រាប់ការការពារសិទ្ធិមនុស្ស និងសេរីភាពជាសារវន្ត ដាក់ឱ្យចុះហត្ថលេខានៅ ថ្ងៃទី២ ខែតុលា ឆ្នាំ២០១៣), CETS No 214 (ចូលជាធរមាន ថ្ងៃទី១ ខែសីហា ឆ្នាំ២០១៨)។

គោលដៅនៃសិទ្ធិទទួលបានការជំនុំជម្រះ “ដោយគ្មានការពន្យារពេលមិនចាំបាច់”

៣១, យោងតាមគណៈកម្មាធិការសិទ្ធិមនុស្ស[65]

> សិទ្ធិរបស់ជនជាប់ចោទក្នុងការជំនុំជម្រះដោយគ្មានការពន្យារពេលមិនសមស្រប មានចែងក្នុងមាត្រា ១៤ កថាខណ្ឌ ៣(គ) ដែលតាក់តែងឡើងដើម្បីជៀសវាងពីការទុកឱ្យបុគ្គលម្នាក់ស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជា អំពីជោគវាសនារបស់ខ្លួន និងប្រសិនបើត្រូវបានឃុំឃាំង ក្នុងអំឡុងពេលជំនុំជម្រះដើម្បីធានាការដកហូតសេរីភាព

---

[64] Krit Zeegers *International Criminal Tribunals និង Human Rights Law: Adherence និង Contextualization* (Springer, ឆ្នាំ២០១៦) ទំព័រ ២៩១ “មិនមានភស្តុតាងដែលថា ពាក្យពេចន៍ខុសគ្នាធ្វើឱ្យមានការបកស្រាយផ្ទុយគ្នាឡើយ ប៉ុន្តែផ្ទុយទៅវិញនោះទេ។ ដូចដែលបានឃើញនៅផ្នែកខាងក្រោម ការបកស្រាយរបស់ តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការ IACtHR និងតុលាការ HRC ទៅលើបទប្បញ្ញត្តិរបស់ពួកគេ មានភាពប្រហែលគ្នាខ្លាំង។ ជាលទ្ធផល ឃ្លាទាំងអស់នេះអាចប្រើប្រាស់ជំនួសគ្នាទៅវិញទៅមក” Marc Henzelin *និង* Heloise Rordorf, “នៅពេលណាដែលរយៈពេលនៃកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ ទៅជាលែងសមស្រប បើយោងតាមតុលាការសិទ្ធិមនុស្សអឺរ៉ុប’ (ឆ្នាំ២០១៤) 5(1) *New Journal of European Criminal Law* កថាខណ្ឌ ៧៨, កថាខណ្ឌ ៨0 ដកស្រង់ Trechsel, *Human Rights in Criminal Proceedings* (Oxford University Press, ឆ្នាំ២00៥) កថាខណ្ឌ ១៣៥។

[65] គណកម្មាធិការសិទ្ធិមនុស្ស មតិទូទៅលេខ ៣១៖ មាត្រា ១៤ សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ 90th sess, UN Doc CCPR/C/GR/32 (ថ្ងៃទី២៣ ខែសីហា ឆ្នាំ២00៧) ១0, កថាខណ្ឌ៣៥។

បែបនេះ មិនលើសពីភាពចាំបាច់ ក្នុងកាលៈទេសៈនៃរឿងក្តីជាក់លាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីបម្រើប្រយោជន៍នៃយុត្តិធម៌ (ដោយគូសបញ្ជាក់បន្ថែម)។

៣២, លើសពីនេះទៀត តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា រដ្ឋជាសមាជិកមានកាតព្វកិច្ចក្នុងការធានាថា ប្រព័ន្ធច្បាប់របស់ពួកគេត្រូវបានរៀបចំឡើងដើម្បីផ្តល់ភាពស្ថាពរមួយចំពោះអ្នកជាក់បណ្តឹងនៅក្នុងរយៈពេលសមស្របមួយ។ ក្នុងរឿងក្តី Frydlender តទល់នឹង France (ឆ្នាំ២០០០) តុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចថា[66]

> *«រដ្ឋជាហត្ថលេខីត្រូវរៀបចំប្រព័ន្ធច្បាប់របស់ខ្លួន ដើម្បីឱ្យតុលាការអាចធានាការពារថា បុគ្គលគ្រប់រូបមានសិទ្ធិទទួលបានសេចក្តីសម្រេចជាស្ថាពរ នៅក្នុងពេលវេលាសមស្របមួយក្នុងការសម្រេចលើសិទ្ធិ និងកាតព្វកិច្ចរដ្ឋប្បវេណីរបស់គេ (ដោយគូសបញ្ជាក់បន្ថែម)។»*

[66] *Frydlender តទល់នឹង ប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះតុលាការកំពូល ពាក្យសុំលេខ 30979/96 ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០) កថាខណ្ឌ ៤៥ ដកស្រង់ *Caillot តទល់នឹង ប្រទេសបារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបី ពាក្យសុំលេខ 36932/97 ថ្ងៃទី៤ ខែមិថុនា ឆ្នាំ១៩៩៩) កថាខណ្ឌ២៧។

៣៣, ការមិនរក្សាការពារសិទ្ធិ អាចបង្កបញ្ហាដល់ប្រសិទ្ធភាព និងភាពជឿទុកចិត្តរបស់ ប្រព័ន្ធយុត្តិធម៌ជាតិ។ ក្នុងរឿងក្តី Dimitrov និង Hamanov តទល់នឹង Bulgaria តុលាការបានសម្រេចថា[67]

> *«"ពេលវេលាសមស្រប" ដែលជាការធានាក្នុងមាត្រា ៦ (១) មានភារកិច្ចធានានូវជំនឿទុកចិត្តរបស់សាធារណជននៅក្នុងរដ្ឋបាលតុលាការ។ គោលបំណងដទៃផ្សេងទៀតនៃការធានាការពារ គឺដើម្បីការពារភាគីទាំងអស់នៃកិច្ចដំណើរការនីតិវិធីតុលាការប្រឆាំងនឹងការពន្យារពេលនីតិវិធីហួសហេតុ នៅក្នុងបញ្ហាព្រហ្មទណ្ឌ ជាពិសេស ការធានានេះបង្កើតឡើង ដើម្បីជៀសវាងពីបុគ្គលម្នាក់ ដែលត្រូវបានចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ត្រូវស្ថិតនៅយូរពេកក្នុងស្ថានភាពមិនប្រាកដប្រជាអំពីជោគវាសនារបស់ខ្លួន...ចំណុចនេះបានបញ្ជាក់ពីសារៈសំខាន់នៃដំណើរការរដ្ឋបាលតុលាការដោយមិនមានការពន្យារពេលដែលអាច បង្កបញ្ហាដល់ប្រសិទ្ធភាព និងភាពជឿទុកចិត្ត។ (លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)។»*

៣៤, ចំណុចនេះត្រូវបានបញ្ជាក់ច្រើនដងនៅក្នុងសេចក្តីសម្រេចផ្សេងៗ ជាច្រើនរបស់តុលាការសិទ្ធិមនុស្សអឺរ៉ុប[68]។

---

[67] រឿងក្តី *Dimitrov និង Hamanov តទល់នឹង ប្រទេសប៊ុលហ្គារី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប ផ្នែកទីបួន ពាក្យសុំលេខ 48059/06 *និង* 2708/09 ថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១១) កថាខណ្ឌ៧០។

[68] *Guincho តទល់នឹង ប្រទេសព័រទុយហ្គាល់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 8990/80 ថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៨៤) កថាខណ្ឌ ៣៨ *Zimmermann និង Steiner តទល់នឹង ប្រទេសស្វីស* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 8737/79 ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ ១៩៨៣) កថាខណ្ឌ២៩។ រឿងក្តី *H តទល់នឹង ប្រទេសពារាំង* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 10073/82 ថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៨៩) កថាខណ្ឌ៥៨។ រឿងក្តី *Moreira de Azevedo តទល់នឹង ប្រទេសព័រទុយហ្គាល់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 11296/84 ថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៩១) កថាខណ្ឌ៧៤។ រឿងក្តី *Katte Klitsche de la Grange តទល់នឹង ប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 12539/86 ថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៤) កថាខណ្ឌ៦១។ រឿងក្តី *Bottazzi តទល់នឹង ប្រទេសអ៊ីតាលី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 34884/97 ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៩) កថាខណ្ឌ២២។ រឿងក្តី *Niederboster តទល់នឹង ប្រទេសអាល្លឺម៉ង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 39547/98 ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣) កថាខណ្ឌ៤៤។ រឿងក្តី *Konstantin Stefanov តទល់នឹង ប្រទេសប៊ុលហ្គារី* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 35399/05 ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥) កថាខណ្ឌ៦៤។ "ច្បាប់ស្វែងរកគោលដៅស្របច្បាប់ក្នុងការធានាឱ្យមានដំណើរការដ៏រលូននៃប្រព័ន្ធយុត្តិធម៌...ដោយមានការយោងបន្ថែមទៅសារៈសំខាន់នៃរដ្ឋបាលតុលាការ ដោយមិនមានការពន្យារពេល ដែលអាចជះឥទ្ធិពលដល់ប្រសិទ្ធភាព និងជំនឿទុកចិត្តចំពោះតុលាការ)។ តុលាការទទួលស្គាល់ថា ជាការមិនអាចប្រកែកបាន ដើម្បីជាផលប្រយោជន៍ទូទៅរបស់សង្គម ត្រូវមានប្រព័ន្ធយុត្តិធម៌មួយដែលដំណើរការទៅដោយប្រសិទ្ធភាព ហើយចំណុចនេះរួមបញ្ចូលកិច្ចដំណើរការនីតិវិធីតុលាការ ដែលមិនមានការរាំងស្ទះ ដោយការអូសបន្លាយពេលមិនសមហេតុផល" (លុបចោលការដកស្រង់)។

សិទ្ធិតាមលក្ខន្តិក:តុលាការព្រហ្មទណ្ឌអន្តរជាតិនានា

៣៥, សិទ្ធិនេះត្រូវបានធានាការពារតាមលក្ខន្តិក:ព្រហ្មទណ្ឌអន្តរជាតិនីមួយៗ។ ពាក្យពេចន៍ដូចគ្នា ត្រូវបានប្រើប្រាស់នៅក្នុងមាត្រា ២០(៤)(គ) នៃលក្ខន្តិក:តុលាការអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (តុលាការ ICTR)[69] មាត្រា ២១(៤)(គ) នៃលក្ខន្តិក:តុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (តុលាការ ICTY)[70] មាត្រា ៦៧(១)(គ) នៃលក្ខន្តិក:ទីក្រុងរ៉ូម[71] មាត្រា១៧(៤)(គ) នៃលក្ខន្តិក:តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (តុលាការ SCSL)[72]

---

[69] លេខ SC Res 955, ឯកសារ អ.ស.ប លេខ S/RES/955 (ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៩៤) ឧបសម្ព័ន្ធ ("លក្ខន្តិក:នៃតុលាការអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា) មាត្រា ២០(៤)(គ) "ត្រូវធ្វើការជំនុំជម្រះដោយគ្មានការពន្យារពេលដោយមិនចាំបាច់"។

[70] ឯកសារ អ.ស.ប លេខ S/RES/1877 (ថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០០៩) ("លក្ខន្តិក:តុលាការ ICTY") មាត្រា ២១(៤)(គ) "ត្រូវធ្វើការជំនុំជម្រះ ដោយគ្មានការពន្យារពេលដែលមិនចាំបាច់"។

[71] លក្ខន្តិក:ទីក្រុងរ៉ូម របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដាក់ឱ្យចុះហត្ថលេខានៅ ថ្ងៃទី៧ ខែកក្កដា ឆ្នាំ១៩៩៨, 2187 UNTS 90 (ចូលជាធរមានថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២) "លក្ខន្តិក:ទីក្រុងរ៉ូម") មាត្រា ៦៧(១)(គ) "ត្រូវធ្វើការជំនុំជម្រះ ដោយគ្មានការពន្យារពេលដែលមិនសមស្រប"។

[72] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលសេរ៉ាឡេអូន ស្តីពីការបង្កើតតុលាការពិសេស សម្រាប់ប្រទេសសេរ៉ាឡេអូន ចុះហត្ថលេខានៅ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០០២ 2178 UNTS 137 (ចូលជាធរមានថ្ងៃទី១២ ខែមេសា ឆ្នាំ២០០២) ឧបសម្ព័ន្ធ ("លក្ខន្តិក:របស់តុលាការពិសេស សម្រាប់ប្រទេសសេរ៉ាឡេអូន") មាត្រា ១៧(៤)(គ) "ត្រូវធ្វើការជំនុំជម្រះ ដោយគ្មានការពន្យារពេលដែលមិនសមស្រប"។

មាត្រា ១៦(៤)(គ) នៃលក្ខន្តិក:តុលាការពិសេសសម្រាប់ប្រទេសលីបង់ (តុលាការ STL)[73] មាត្រា ១៩(៤)(គ) នៃលក្ខន្តិក:យន្តការដែលនៅសេសសល់ជាអន្តរជាតិសម្រាប់តុលាការព្រហ្មទណ្ឌ (តុលាការ MICT)។

សិទ្ធិតាមក្រមព្រហ្មទណ្ឌកម្ពុជា

៣៦, មាត្រា ៣៥ថ្មី(គ) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[74] ចែងថា ជនជាប់ចោទ "ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ"។ គួរឱ្យចាប់អារម្មណ៍ពាក្យ "ការអូសបន្លាយ" មិនមានបន្តដោយពាក្យសង្កត់ន័យ (qualifier) "មិនចាំបាច់" ហើយក៏មិនមានការយោងទៅរក "ពេលវេលាសមស្រប" ដែរ។ ការបកប្រែដោយត្រង់លើ "គ្មានការអូសបន្លាយ" បង្ហាញថា កិច្ចដំណើរការនីតិវិធីតុលាការ ចាំបាច់ត្រូវតែឆាប់រហ័សភ្លាមៗ ឬបន្ទាន់។ ទោះបីជាបែបនេះក្តី មាត្រា ៣៥ថ្មី (គ) បានចែងថា:

[73] SC Res 1757, ឯកសារ អ.ស.ប លេខ S/RES/1757 (ថ្ងៃទី២០ ខែឧសភា ឆ្នាំ ២០០៧) ("លក្ខន្តិក:របស់តុលាការពិសេស សម្រាប់ប្រទេសលីបង់") មាត្រា ១៦(៤)(គ) "ត្រូវធ្វើការជំនុំជម្រះ ដោយគ្មានការពន្យារពេលដែលមិនសមស្រប"។

[74] ច្បាប់ស្តីពីការបង្កើតឱ្យមាន អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ បូកជាមួយច្បាប់វិសោធនកម្ម ដែលបានប្រកាសឱ្យប្រើ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នាសមស្របតាម មាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិ នយោបាយ។

៣៧, លើសពីនេះទៀត វិធាន ២១(៤) នៃវិធានផ្ទៃក្នុងចែងថា កិច្ចដំណើរការនីតិវិធីត្រូវបញ្ចប់ "ក្នុងរយៈពេលមួយសមស្រប"។ ដោយចង ចាំពីចំណុចនេះ វាហាក់ដូចជាថា អ្នកតាក់តែងសេចក្តីព្រាងច្បាប់ មានចេតនាចង់ឱ្យមាត្រា ៣៥ ថ្មី (គ) ត្រូវបានបកស្រាយ ក្នុងលក្ខណៈដូចគ្នានឹង មាត្រា១៤(៣) នៃកតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

សិទ្ធិតាមក្រមនីតិវិធីព្រហ្មទណ្ឌបារាំង

៣៨, ការយោងទៅរក "ពេលវេលាសមស្រប" មាននៅក្នុងមាត្រាបឋមនៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង[75] ដែលចែងថា៖

បុព្វកថា

ការចោទប្រកាន់ចំពោះបុគ្គលបែបនេះ គឺជាកម្មវត្ថុនៃការឈានទៅដល់សាលក្រមស្ថាពរក្នុងពេលវេលាសមស្រប (ដោយគួសបញ្ជាក់បន្ថែម)។

---

[75] *Code de Procedure Penale* [ក្រមនីតិវិធីព្រហ្មទណ្ឌ] (*ប្រទេសបារាំង*) បុព្វកថា។

៣៩, សូមកត់សម្គាល់ថា បុព្វកថាដែលមានលក្ខខណ្ឌតម្រូវ “ពេលវេលាសមស្រប” ត្រូវបានចាប់ផ្តើមឡើងតាមរយៈច្បាប់ស្តីពីសច្ចធារណ៍នៃនិរទោស ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០។

គោលការណ៍ពាក់ព័ន្ធនានាក្នុងការសម្រេចលើភាពសមស្រប

៤0, មិនមានគោលការណ៍ណែនាំទូទៅដែលបានកំណត់ណាមួយអំពីពេលវេលាដែលអាចអនុញ្ញាតបាន តាមសិទ្ធិនេះឡើយ។ ការវាយតម្លៃលើ “ពេលវេលាសមស្រប” មានការប្រែប្រួលខ្លាំង អាស្រ័យលើកាលៈទេសៈនៃរឿងក្តី[76]។

៤១, លើសពីនេះទៀតទោះបីជាមានកាតព្វកិច្ចសម្រាប់រដ្ឋក្នុងការពន្លឿនកិច្ចដំណើរការនីតិវិធីតុលាការ ជាការចាំបាច់ត្រូវមានការថ្លឹងថ្លែងដោយយុត្តិធម៌ធៀបជាមួយនឹង “គោលការណ៍ទូទៅនៃរដ្ឋបាលតុលាការដែលសមស្រប”[77]។

---

[76] រឿងក្តី *Guincho តទល់នឹង ប្រទេសព័រទុយហ្គាល់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 8990/80 ថ្ងៃទី១0 ខែកក្កដា ឆ្នាំ១៩៨៤) កថាខណ្ឌ៣១។ រឿងក្តី *Zimmermann និង Steiner តទល់នឹង ប្រទេសស្វីស* (តុលាការសិទ្ធិមនុស្សអឺរ៉ុប អង្គជំនុំជម្រះសាលាដំបូង ពាក្យសុំលេខ 8737/79 ថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៨៣) កថាខណ្ឌ២៤។

[77] រឿងក្តី *Boddaert តទល់នឹង ប្រទេសប៊ែលហ្សិក* (តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការពេញអង្គ ពាក្យសុំលេខ 12919/87 ថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៩២) កថាខណ្ឌ ៣៩។

តើពេលវេលាដែលត្រូវធ្វើការពិចារណា ចាប់ផ្តើមនៅពេលណា?

៤២, នៅក្នុងបរិបទនៃរឿងក្តីព្រហ្មទណ្ឌ ពេលវេលាដែលត្រូវធ្វើការពិចារណា ត្រូវអនុវត្តចំពោះកិច្ចដំណើរការនីតិវិធីទាំងមូល[78]។ ជាទូទៅ ពេលវេលានេះចាប់ផ្តើមនៅថ្ងៃដែលបុគ្គលនោះត្រូវបានចោទប្រកាន់[79]។ ទោះបីជាយ៉ាងនេះក្តីតុលាការសិទ្ធិមនុស្សអឺរ៉ុបបានសម្រេចនៅក្នុងរឿងក្តីជាច្រើនថា រយៈពេលនៃ "ពេលវេលាសមស្រប" អាចចាប់ផ្តើមលឿនជាងនេះ។ បើតាមទស្សនៈរបស់តុលាការរយៈពេលដែលត្រូវធ្វើការពិចារណាចាប់ផ្តើមនៅពេលដែល "ស្ថានភាពរបស់ជនសង្ស័យ ត្រូវទទួលផលប៉ះពាល់ធ្ងន់ធ្ងរ" ដោយសារវិធានការផ្សេងៗ[80]។ ឧទាហរណ៍ នៅពេលដែលជនសង្ស័យ

---

[78] រឿងក្តី *Konig តទល់នឹង ប្រទេសអាល្លឺម៉ង់* (តុលាការសិទ្ធិមនុស្សអឺរ៉ុប តុលាការពេញអង្គ ពាក្យសុំលេខ 6232/73 ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៨) កថាខណ្ឌ៩៨។ "តុលាការបានសម្រេចថា ចំពោះបញ្ហាព្រហ្មទណ្ឌ រយៈពេលនេះគ្របដណ្តប់លើ កិច្ចដំណើរការនីតិវិធីដែលមានបញ្ហាទាំងស្រុង រួមទាំងកិច្ចដំណើរការនីតិវិធីប្តឹងសាទុក្ខ"។

[201] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Limaj និងអ្នកផ្សេងទៀត (សាលជីកា)* (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះតុលាការកំពូល រឿងក្តីលេខ IT-03-66-A ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧) ១១៨ កថាខណ្ឌ ៣ (ចៅក្រម Shahabudden) ដកស្រង់រឿងក្តី *Adams Wrecking Co. តទល់នឹងសហរដ្ឋអាមេរិក* 434 U.S. 275, 284-285 (ឆ្នាំ១៩៧៨) ដកស្រង់ រឿងក្តីសហរដ្ឋអាមេរិក *តទល់នឹង Bass*, 404 U.S. 336, 348 (ឆ្នាំ១៩៧១)។

៩២, ផ្ទុយទៅវិញចៅក្រម Schomburg មិនយល់ស្របជាមួយមតិខាងលើ ដោយលើកទឡ្ហីករណ៍ថា គោលការណ៍គឺកម្រិតត្រឹមតែបញ្ហាអង្គហេតុ ដោយលោកចៅក្រមបញ្ជាក់ថា៖

«ការអនុវត្តគោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ កម្រិតត្រឹមតែការសម្រេចលើអង្គហេតុ រួមទាំងអង្គហេតុផ្លូវច្បាប់ប៉ុន្តែមិនអាចពង្រីកដល់ការសម្រេច លើបញ្ហាអង្គច្បាប់ឡើយ។ ហេតុដូច្នេះ ខ្ញុំមិនអាចយល់ស្របជាមួយចៅក្រម Shahabuddeen លើបញ្ហានេះបានទេ។ (លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)[202] *។ នៅក្នុងកម្រិតជាតិ ក៏មានយុត្តិសាស្ត្រដែលបានកំណត់ទុកជាស្រេចដែលថា គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ “ទាក់ទងតែជាមួយនឹងអង្គហេតុ” (លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)*[203] *។*

---

[202] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Limaj និងអ្នកផ្សេងទៀត (សាលដីកា)* (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះតុលាការកំពូល រឿងក្តីលេខ IT-03-66-A ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧) ១២៤ កថាខណ្ឌ ១៥ (ចៅក្រម Judge Schomburg)។

[203] រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Limaj និងអ្នកផ្សេងទៀត (សាលដីកា)* (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះតុលាការកំពូល រឿងក្តីលេខ IT-03-66-A ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧) ១២៤ កថាខណ្ឌ ១៧ (ចៅក្រម Schomburg) ដកស្រង់ Bundesgerichtshof [BGH] [តុលាការកំពូលសហព័ន្ធ (អាល្លឺម៉ង់)] ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៥៩, 14 Entscheidungen

ទោះជាយ៉ាងនេះក្តី ជាករណីពិសេសមានបញ្ហាអង្គហេតុដែលពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គច្បាប់ ដូចជាអង្គ ហេតុផ្លូវច្បាប់ផងដែរ។ អង្គហេតុផ្លូវច្បាប់បែបនេះ ដូចជា អត្ថិភាពនៃលក្ខន្តិក:ជាតិ ការអនុវត្តរបស់រដ្ឋ ច្បាប់ទំនៀមទម្លាប់ ឬច្បាប់បរទេសជាទូទៅ គឺជាកម្មវត្ថុនៃដំណើការស្វែងរកការពិត របស់តុលាការ ព្រោះសិទ្ធិអំណាចក្នុងការបកស្រាយ និយាមទាំងអស់នេះ មិនត្រូវបានផ្តល់ដល់តុលាការអន្តរជាតិឡើយ។ ក្នុងករណីវិមតិសង្ស័យទៅលើអង្គហេតុផ្លូវច្បាប់បែបនេះតុលាការអន្តរជាតិចាំបាច់ត្រូវតែសម្រេចជាប្រយោជន៍ដល់ជនជាប់ចោទ។ (ដោយគូសបញ្ជាក់បន្ថែម)[204]។»

តុលាការព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍អនុវត្តចំពោះទាំង បញ្ហាអង្គហេតុ និងបញ្ហាអង្គច្បាប់

៩៣, នៅក្នុងរឿងក្តី Katanga អង្គជំនុំជម្រះតុលាការកំពូលបានសម្រេច ថា គោលការណ៍ត្រូវពង្រីកឱ្យហួសពី “បរិបទនៃច្បាប់

---

des Bundesgerichtshofs in Strafsachen [BGHSt] 68 (73), បកប្រែមិនផ្លូវការ។ សូមមើលផងដែរ Bundesgerichtshof [BGH] [តុលាការកំពូលសហព័ន្ធ (អាល្លឺម៉ង់)] ចុះថ្ងៃទី៣0 ខែសីហា ឆ្នាំ២00៦, 12 NSTZ-RECHTSPRECHUNGS-REPORT [NSTZ-RR] 43-45 (2007)។

[204] រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Limaj និងអ្នកផ្សេងទៀត (សាលដីកា)* (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អង្គជំនុំជម្រះតុលាការកំពូល រឿងក្តីលេខ IT-03-66-A ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២00៧) ១២៥ កថាខណ្ឌ ២0 (ចៅក្រម Schomburg)។

ព្រហ្មទណ្ឌសារធាតុ” ហើយឈានចូលទៅដល់ “វិស័យវិធាននីតិវិធី”[205]។

«គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ គឺជាគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ ដែលអនុវត្តជាទូទៅនៅចំពោះមុខតុលាការ ICTY និងតុលាការ ICTR។ គោលការណ៍នេះអាចអនុវត្តបានផងដែរចំពោះនីតិវិធីនៅចំពោះមុខតុលាការព្រហ្មទណ្ឌអន្តរជាតិ។ ទោះបីជាទូ ទៅគោលការណ៍នេះត្រូវបានយោងទៅ នៅក្នុងបរិបទច្បាប់ព្រហ្មទណ្ឌសារធាតុក្តី ប៉ុន្តែមានការលើកឡើងថាគោល ការណ៍នេះត្រូវអនុវត្តផងដែរ នៅក្នុងវិស័យវិធាននីតិវិធី។ មាត្រា ២២/២ នៃលក្ខន្តិក:បានអនុម័តយកវិធីសាស្ត្រ វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ ទាក់ទងជាមួយនឹងនិយមន័យនៃឧក្រិដ្ឋកម្ម។ មានការលើកឡើងថាវិធីសាស្ត្រនេះបើតាមសទិសន័យអាចអនុវត្តបានផងដែរចំពោះ និយាមនីតិវិធី។ ចំណុចចុងក្រោយនេះត្រូវបានវិភាគផងដែរក្នុងគោលដៅដែលថាសិទ្ធិនិងផលប្រយោជន៍របស់ជនជាប់ចោទត្រូវបាន

[205] រឿងក្តីរដ្ឋអាជ្ញា *តទល់នឹង Katanga (សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីពាក់ព័ន្ធនឹងភាសា)* (តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូល រឿងក្តីលេខ ICC-01/04-01/07 ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨) កថាខណ្ឌ ៥៨។

ការពារយ៉ាងពេញលេញនៅក្នុងកិច្ចដំណើរការនីតិវិធី។(លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)។»

តុលាការព្រហ្មទណ្ឌអន្តរជាតិ គោលការណ៍អនុវត្តនៅគ្រប់ដំណាក់កាល

៩៤, នៅក្នុងរឿងក្តី Bemba អង្គបុរេជំនុំជម្រះបានសម្រេចថា "គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ គឺជាធាតុផ្សំមួយនៃសច្ចធារណ៍នៃនិរទោស ដែលជាគោលការណ៍ទូទៅនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ត្រូវអនុវត្តក្នុងករណីចាំបាច់ ចំពោះគ្រប់ដំណាក់កាលទាំងអស់ នៃកិច្ចដំណើរការនីតិវិធី រួមទាំងដំណាក់កាលមុនពេលជំនុំជម្រះផងដែរ"[206]។

អ.វ.ត.ក វិសាលភាពនៃគោលការណ៍ ផ្អែកលើអង្គជំនុំជម្រះតុលាការកំពូល

៩៥, អង្គជំនុំជម្រះតុលាការកំពូលបានកត់សម្គាល់ថា គោលការណ៍គឺជាធាតុមួយនៃសច្ចធារណ៍នៃនិរទោស ដែលត្រូវបានធានាការពារអនុ-លោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

---

[206] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Bemba (សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិក:ទីក្រុងរ៉ូមទៅលើការចោទប្រកាន់របស់រដ្ឋអាជ្ញាប្រឆាំងនឹង Jean-Pierre Bemba Gombo)* (តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គបុរេជំនុំជម្រះទីពីរ រឿងក្តីលេខ ICC- 01/05-01/08-424 ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩) កថាខណ្ឌ ៣១។

[207]។ លើសពីនេះទៀត អង្គជំនុំជម្រះបានត្រួតពិនិត្យចំនួនពីរដង ផ្សេងគ្នាទៅលើវិសាលភាពនៃគោលការណ៍ ពាក់ព័ន្ធទាំងបញ្ហា អង្គច្បាប់ និងបញ្ហាអង្គហេតុ។

៩៦, នៅក្នុងសេចក្តីសម្រេចខែមិថុនា ឆ្នាំ២០១១ អង្គជំនុំជម្រះបាន សម្រេចថា[208]

«ចំពោះគោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ ដល់ជនជាប់ចោទ អាចអនុវត្តបានចំពោះស្ថានភាពលំបាកនៃ អត្ថន័យច្បាប់ គោលការណ៍នេះត្រូវកម្រិតត្រឹមតែភាពមន្ទិល សង្ស័យដែលនៅតែមាន ក្រោយការបកស្រាយ។ ហេតុដូច្នេះ គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ ចោទ ត្រូវអនុវត្តដោយត្រឹមត្រូវចំពោះមន្ទិលសង្ស័យអំពីខ្លឹម សារនៃបទជ្ឈានគតិយុត្តិ ដែលនៅតែមានក្រោយការអនុវត្ត វិធាននៃការបកស្រាយតាមប្រព័ន្ធច្បាប់ស៊ីវិល ដោយធ្វើការ ពិចារណាទៅលើពាក្យពេចន៍នៃបទប្បញ្ញត្តិ ការដាក់បញ្ចូលក្នុង ប្រព័ន្ធ រួមមានការជាប់ទាក់ទងទៅនឹងគោលការណ៍សំខាន់ៗ

---

[207] សំណុំរឿង ០០៤ ឯកសារ D351/6.1.35 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ទំព័រ ២១ កថាខណ្ឌ ៣១។

[208] សំណុំរឿង ០០៤ ឯកសារ D351/6.1.35 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗ របស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ទំព័រ ២១ កថាខណ្ឌ ៣១។

ដែលជាមូលដ្ឋានគ្រឹះ និងគោលបំណងរបស់គោល ការណ៍នេះ។ ដូចនេះតាមការអនុវត្តជាក់ស្តែង គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ មិនមានភាពចាំបាច់ក្នុងការដោះស្រាយទៅលើភាពខ្វះចន្លោះនៃច្បាប់ឡើយ ប៉ុន្តែអាចដើរតួក្នុងករណីដែលមានវិវាទបទដ្ឋានច្បាប់នានា។ (លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)។»

៩៣, នៅក្នុងសេចក្តីសម្រេចដដែលនេះ អង្គជំនុំជម្រះបានពិភាក្សាពីទំនាក់ទំនងរវាងវិធាន ២១(១) នៃវិធានផ្ទៃក្នុងជាមួយនឹងគោលការណ៍ ហើយអង្គជំនុំជម្រះបានសម្រេចថា[209]

«អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា វិធាន២១ (១)នៃវិធានផ្ទៃក្នុង ត្រូវតែបានយល់ថា ការបកស្រាយវិធានផ្ទៃក្នុង មិនត្រូវឱ្យមានការរំលោភលើប្រយោជន៍ណាមួយរបស់ជនជាប់ចោទ ដែលកើតចេញពីសិទ្ធិសារវ័ន្ត ត្រូវបានធានានៅក្នុងលក្ខន្តិក: និងលិខិតុបករណ៍អន្តរជាតិនានាជាធរមាន មានដូចជាការសន្មតទុកជាមុនថាគ្មានទោស សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ សិទ្ធិនៅស្ងៀមមិនឆ្លើយតប សិទ្ធិទទួលបានការការពារខ្លួន។ ដូច្នេះក្នុងការបង្កើតអត្ថន័យគតិយុត្តិនៃវិធានផ្ទៃក្នុង ស្ថាប័នមានសមត្ថកិច្ចបកស្រាយគួរតែធ្វើ

---

[209] សំណុំរឿង ០០៤ ឯកសារ D351/6.1.35 សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ទំព័រ ២០-២១ កថាខណ្ឌ ៣០។

ឱ្យស្របតាមវិធានៃការបក ស្រាយច្បាប់ដោយពិចារណាលើ គោលការណ៍ទូទៅទាំងអស់ ក្នុងចំណោមគោលការណ៍ផ្សេងៗ ដែលការពារសិទ្ធិរបស់ជនជាប់ចោទហើយជាលទ្ធផលចុងក្រោ- យគួរតែវាយតម្លៃនៅក្នុងក្របខណ្ឌនៃសិទ្ធិទាំងនោះ។ គោល បំណងនៃការបក ស្រាយចេញពីវិ ធាន២១ (១) មិនមានន័យថា វិធានផ្ទៃក្នុងត្រូវតែបកស្រាយ ក្នុងន័យផ្តល់ផលប្រយោជន៍ដល់ ជនជាប់ចោទដោយស្វ័យប្រវត្តិ នៅក្នុងគ្រប់ស្ថានភាពជាក់លាក់ ដែលកើតចេញពីការបកស្រាយនៃវិធានផ្ទៃក្នុងឡើយ។ (ដោយ គូសបញ្ជាក់បន្ថែម)»

៩៨, នៅក្នុងសេចក្តីសម្រេចថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ អង្គជំនុំជម្រះ បានពិភាក្សាអំពី វិសាលភាពនៃគោលការណ៍ ទាក់ទងទៅនឹងការ វាយតម្លៃលើភស្តុតាង ហើយអង្គជំនុំជម្រះបានសម្រេចថា[210]

«បើទោះបីជាការពិតដែលថា ភាពមិនស៊ីសង្វាក់គ្នាក្នុងចំ ណោមភស្តុតាងដែលអង្គជំនុំជម្រះបានសំអាងទៅលើនោះ ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាពុំឃើញថា សេចក្តីសន្និដ្ឋានរបស់ អង្គជំនុំជម្រះសាលាដំបូងមានលក្ខណៈ ពុំសមហេតុផល ឬរំលោភបំពានលើគោលការណ៍វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ នោះឡើយ។ គោល

[210] សំណុំរឿង ០០២ ឯកសារ F36 សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ ទំព័រ ៥៣៨ កថាខណ្ឌ ៨៤១។

ការណ៍នេះពុំអនុវត្ត ដោយផ្អែកទៅលើកម្រិតនៃភស្តុតាងនីមួយៗឡើយ ដែលមានន័យថា ភស្តុតាងនីមួយៗគប្បីត្រូវបកស្រាយថា មានកម្រិតជាក់បន្ទុកតិចតួច បំផុត។ ផ្ទុយទៅវិញ តុលាការអង្គហេតុគប្បីពិចារណា ថាតើនៅពេលវាយតម្លៃនៃភស្តុតាងនោះ ជារួមមានលក្ខណៈគ្រប់គ្រាន់ សម្រាប់គាំទ្រដល់ការឈរលើរឿង ឱ្យហួសពីវិមតិសង្ស័យដែរឬយ៉ាងណា។ ភស្តុតាងនីមួយៗអាចបំពេញគ្នា ទៅវិញទៅមក និងនាំឱ្យតុលាការអង្គហេតុ អាចធ្វើសេចក្តីសន្និដ្ឋានបានថា លក្ខខណ្ឌតម្រូវមួយត្រូវបានបំពេញ។ លើកលែងតែក្នុងករណីដែលក្រោយពីបានធ្វើការវាយតម្លៃភស្តុតាងជារួមរួចហើយ នៅតែមានវិមតិសង្ស័យទៀត នោះទើបគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ តម្រូវថាតុលាការអង្គហេតុពុំអាចធ្វើការសម្រេចណាមួយ ដែលធ្វើឱ្យប៉ះពាល់ដល់ជនជាប់ចោទឡើយ។ (ដោយគូសបញ្ជាក់បន្ថែម)»

អ.វ.ត.ក វិសាលភាពនៃគោលការណ៍ ផ្អែកលើអង្គបុរេជំនុំជម្រះ

៩៩, នៅក្នុងសេចក្តីសម្រេចថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៧ អង្គបុរេជំនុំជម្រះបានសម្រេចថា[211]

[211] សំណុំរឿង ០០៣ ឯកសារ D87/2/1.7/1/1/7 ។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ជីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

«គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ... គោលការណ៍នេះជាវិធាននៃភស្តុតាង និងពុំមែនជាការបកស្រាយច្បាប់ទេ ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិ និងអង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់រួចមកហើយ។ (លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)»

១00, ទោះជាយ៉ាងណាក្តី នៅក្នុងសេចក្តីសម្រេចបន្ទាប់ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ (សេចក្តីពិចារណាលើ បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ) ចៅក្រមអន្តរជាតិហាក់ដូចជាពិចារណាលើលទ្ធភាពដែលថា គោលការណ៍អនុវត្តបានចំពោះ "ការបកស្រាយច្បាប់" ដោយចៅក្រមអន្តរជាតិបញ្ជាក់ថា[212]

«ចៅក្រមអន្តរជាតិសូមបញ្ជាក់សារជាថ្មីថា ជាចម្បង គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ ដល់ជនជាប់ចោទ គឺជាវិធាននៃភស្តុតាង និងមិនមែនជាវិធានបកស្រាយច្បាប់ទេ។ ទីពីរបើទោះបីជា គោលការណ៍វិមតិសង្ស័យត្រូវបាន

និង ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី១0 ខែមេសា ឆ្នាំ២0១៧ ទំព័រ ៤១ កថាខណ្ឌ ៦៥។

[212] សំណុំរឿង 00៣ ឯកសារ D87/2/1.7/1/1/7 ។ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង ចំណងទាក់ទងជាមួយនឹងជម្លោះប្រដាប់អាវុធ ចុះថ្ងៃទី១0 ខែមេសា ឆ្នាំ២0១៧ ទំព័រ ៤១ កថាខណ្ឌ ៦៥។

ជាប្រយោជន៍ ដល់ជនជាប់ចោទ អនុវត្តចំពោះការបកស្រាយ ផ្លូវច្បាប់ក្តី ប៉ុន្តែមិនមានវិមតិសង្ស័យដើម្បីដោះស្រាយឡើយ ព្រោះដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រម ស៊ើបអង្កេតជាតិ គឺមោឃភាពហួសដែនសមត្ថកិច្ច និងគ្មាន អានុភាពគតិយុត្តិឡើយ។ (លប់ចោលការដកស្រង់) (ដោយ គូសបញ្ជាក់បន្ថែម)។»

គោលការណ៍ផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ ពាក់ព័ន្ធនានា សម្រាប់ដោះស្រាយបញ្ហាអង្គច្បាប់

១០១, ដោយសន្មតមួយខណៈសិនថា គោលការណ៍ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ កម្រិតកំណត់ត្រឹមតែបញ្ហា អង្គហេតុ។ អ្នកសិក្សាស្រាវជ្រាវខ្លះបានបង្ហាញថា គោលការណ៍ផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ (favor rei) ដែលមានលក្ខណៈប្រហែលគ្នាខ្លាំង អាចត្រូវបានប្រើប្រាស់ដើម្បីដោះស្រាយបញ្ហាអង្គច្បាប់ ។ជាពិសេស ប្រសិនបើមានវិមតិសង្ស័យ ទាក់ទងនឹងការបកស្រាយនិយមន័យឧក្រិដ្ឋកម្មមួយ និយមន័យនោះគួរត្រូវបានបកស្រាយជាប្រយោជន៍សម្រាប់ជនជាប់ចោទ[213]។

---

[213] Antonio Cassese, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ *Cassese* (Oxford University Press, បោះពុម្ពលើកទី ៣ ឆ្នាំ២០១៣) ៣៥។ Fabian O Raimondo, គោលការណ៍ទូទៅនៃច្បាប់ក្នុងការធ្វើការសម្រេចរបស់តុលាការ និងអង្គជំនុំជម្រះបទ ល្មើសព្រហ្មទណ្ឌអន្តរជាតិ (Martinus Nijhoff, ឆ្នាំ២០០៨) ១១៤។ Rogier Bartels, ការបែងចែកច្បាស់លាស់រវាងការការពារ និងមនុស្សធម៌ៈ

១០២, ជាឧទាហរណ៍ នៅក្នុងរឿងក្តី Akayesu អង្គជំនុំជម្រះសាលាដំ-បូងបានប្រៀបធៀបភាពខុសគ្នាផ្នែកអត្ថន័យរវាងពាក្យជាភាសាអង់គ្លេស “killing” និងពាក្យជាភាសាបារាំង “meurtre” ដែលពាក្យជាភាសា បារាំងបង្ហាញពីធាតុផ្សំចេតនាបន្ថែម។ អង្គជំនុំជម្រះសាលាដំបូង សម្រេចថា ការបកស្រាយដែលស្រាលបំផុតសម្រាប់ជនជាប់ចោទ គួរតែមានអានុភាព ដោយបញ្ជាក់ថា[214]

«ដោយសារតែសក្ខីភាវរណ៍នៃនិរទោសរបស់ជនជាប់ចោទ និងដោយអនុលោមតាម គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ អង្គជំនុំជម្រះសម្រេចថាពាក្យដែលផ្តល់ប្រយោជន៍ដល់ជនជាប់ចោទជាងគេគួរត្រូវបានតម្កល់។»

១០៣, នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ ចៅក្រមចាំបាច់ត្រូវពិចារណាទៅលើគោលការណ៍ផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ តាមមាត្រា ២២(២) នៃលក្ខន្តិក:ទីក្រុងរ៉ូម។ សូមមើលផងដែរ វិធាន ៣(ខ) នៃតុលាការពិសេសសម្រាប់ប្រទេសលីបង់និងវិធាន ២១(១) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

ទំនាក់ទំនង រវាងវិសាលភាពនៃការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ និងយុត្តាធិការលើបទ ល្មើស សង្គ្រាមដែលបានចោទប្រកាន់នៅក្រោមច្បាប់ព្រហ្មទណ្ឌអន្តរជាតិ នៅក្នុង Terry D Gill *និងអ្នកផ្សេងទៀត* (eds), សៀវភៅប្រចាំឆ្នាំនៃច្បាប់មនុស្សធម៌ អន្តរជាតិ ឆ្នាំ ២០១៧ (Asser Press, ឆ្នាំ២០១៩) ៣៧, ៦១។

[214] រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Akayesu (សាលក្រម)* (តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា អង្គជំនុំជម្រះសាលាដំបូង រឿងក្តីលេខ IT-96-4-T ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨) កថាខណ្ឌ ៥០១។

គោលការណ៍ផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទសម្រាប់ដោះស្រាយភាពខ្វះចន្លោះនៃច្បាប់

១០៤, បើយោងតាមលោក Cassese គោលការណ៍ផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ អាចត្រូវបានយកមកប្រើប្រាស់ ដើម្បីការពារសិទ្ធិជនជាប់ចោទ ប្រសិនបើមានភាពខ្វះចន្លោះនៃច្បាប់[215]។

«ខណៈពេលដែលវិធានព្រហ្មទណ្ឌអន្តរជាតិនៅតែជាផ្នែកសំខាន់នៃច្បាប់ ដែលតម្រូវឱ្យមានភាពជាក់លាក់ផ្នែកច្បាប់ និងការកែលម្អសំខាន់ៗខ្លះនៅកម្រិតនិយមន័យ និងគោលការណ៍ទូទៅ។ ដោយគិតពិចារណាទៅលើ លក្ខណៈពិសេសទាំងអស់នេះ ហើយក្នុងពេលជាមួយគ្នាជានាការពារសិទ្ធិរបស់ជនជាប់ចោទ នាពេលថ្មីៗនេះមានសញ្ញាណខ្លះៗដែលបានដើរតួនាទីយ៉ាងធំធេងនៅក្នុងប្រព័ន្ធជាតិភាគច្រើន ៖ ការការពារកំហុសអង្គហេតុ, គោលការណ៍ការបកស្រាយក្នុងន័យចង្អៀត (រាំងការបកស្រាយពង្រីក ឬទូលាយ នូវវិធានព្រហ្មទណ្ឌ), គោលការណ៍ផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ (ដោយកំណត់ថាក្នុងករណីមានសង្ស័យ គួរតែបកស្រាយវិធាននោះ ក្នុងលក្ខណៈដែលផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ)។ សញ្ញាណទាំងអស់នេះ មានតួនាទីជាកត្តាជំទាស់ដែលមាន

[215] Antonio Cassese, ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ *Cassese* (Oxford University Press បោះពុម្ពលើកទី ៣ ឆ្នាំ២០១៣) ២៩។

គោលដៅទូទាត់សងចំពោះកំហុស ឬភាពខ្វះចន្លោះបច្ចុប្បន្ន ក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ។ (ដោយគូសបញ្ជាក់បន្ថែម)»

ចំណងទាក់ទងជាប្រវត្តិសាស្ត្រ ជាមួយនឹងការដោះស្រាយភាពជាប់គាំង ផ្នែកនីតិវិធី

១០៥, បើយោងតាម Wolfgang Ernst គោលការណ៍ វិមតិសង្ស័យត្រូវ បានជាប្រយោជន៍ ដល់ជនជាប់ចោទ កើតឡើងជាយន្តការនីតិវិធី ដើម្បីបំបែកសំឡេងឆ្នោតស្មើគ្នារបស់ចៅក្រម ដោយគាត់បាន បញ្ជាក់ថា[216]

«គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជន ជាប់ចោទ មិនមែនចាប់ផ្តើមឡើងជាគោលការណ៍វិធាននៃភស្តុ តាងឡើយ (សច្ចធារណ៍នៃនិរទោស) ប៉ុន្តែជាដំណោះ ស្រាយ មួយ សម្រាប់សំឡេងឆ្នោតស្មើគ្នារបស់ចៅក្រម។ ជា ទ្រឹស្តី វា អាចញែកចេញយ៉ាងច្បាស់នូវវិធានបំបែកសំឡេងស្មើគ្នា (ចាំ បាច់សម្រាប់តុលាការសហភាគតែប៉ុណ្ណោះ) ពីវិធាននៃភស្តុ តាងដែលទាក់ទងនឹងស្ថានភាពនៃវិមតិសង្ស័យ លើអង្គហេតុ នៃរឿងក្តី។ (ដោយគូសបញ្ជាក់បន្ថែម)។»

---

[216] Wolfgang Ernst, ដំណើរការសម្រេចសេចក្តីរបស់តុលាការ (ជម្រើសជាក្រុម) នៃទម្លាប់តុលាការអឺរ៉ុប (Mohr Siebeck: Tubingen, ឆ្នាំ២០១៦) កថាខណ្ឌ ៥ <https://users.ugent.be/~fdhondt/Ernst_abstract_Collegiate%20Courts%20Voting.pdf>។

១០៦, ប្រហែលគ្នានេះដែរ អ្នកនិពន្ធជាច្រើនរូបបានកត់សម្គាល់ថា សច្ចធារណ៍គតិយុត្តទូទៅ ត្រូវបានបង្កើតឡើងដើម្បីបំបែកភាពជាប់គាំងផ្នែកនីតិវិធី ប្រសិនបើកើតឡើង និងនៅពេលដែលកើតឡើង[217]។

ឃ. ករណីនៃភាពជាប់គាំងតុលាការ នៅតុលាការនិងអង្គជំនុំជម្រះអន្តរជាតិដទៃទៀត

សេចក្តីផ្តើម

១០៧, ការជាប់គាំងផ្នែកតុលាការនៅក្នុងច្បាប់អន្តរជាតិ មានតិចតួចបំផុត។ ជាទូទៅ ចៅក្រមបង្ហាញខ្លួនឯងថាជាសេចក្តីសម្រេចដោយសំឡេងស្មើគ្នាដែលបែកចេញពីគ្នា។ នៅផ្នែកនេះ នឹងពិនិត្យមើលលើករណីជាច្រើននៃការជាប់គាំងផ្នែកតុលាការ នៅអង្គជំនុំជម្រះ និងតុលាការអន្តរជាតិ និងវិធីសាស្ត្រក្នុងការដោះស្រាយភាពជាប់គាំងនោះ។

តុលាការពិសេសសម្រាប់ប្រទេសលីបង់

១០៨, ឧទាហរណ៍ថ្មីៗបំផុតនៃការជាប់គាំងអង្គជំនុំជម្រះបានកើតឡើងនៅតុលាការពិសេសសម្រាប់ប្រទេសលីបង់ (តុលាការ STL)។ ការខ្វែងយោបល់គ្នាតម្រូវឱ្យមានការពិភាក្សាយ៉ាងខ្លីទៅលើប្រវត្តិ

---

[217] សូមមើល Ronald J Allen, ការសន្មតនៅក្នុងវិធានការលើបណ្តឹងរដ្ឋប្បវេណីត្រូវបានពិចារណាសាជាថ្មី (ឆ្នាំ១៩៨១) អត្ថបទវិភាគច្បាប់ 66 *Iowa* ៨៤៣, ៨៤៥។ Raymundo Gama, លក្ខណៈ និងស្ថានភាពនៃការសន្មតនៅក្នុងច្បាប់ និងទឡ្ហីករណ៍ច្បាប់ (ឆ្នាំ២០១៧) 31(3) ទឡ្ហីករណ៍ ៖ ព្រឹត្តបត្តអន្តរជាតិស្តីពីសំអាងហេតុ ៥៥៥, ៥៦៧។

នីតិវិធី។ អង្គជំនុំជម្រះសាលាដំបូង I របស់តុលាការរួមមានចៅក្រមចំនួនបីរូប គឺ ចៅក្រម Janet Nosworthy ចៅក្រម Micheline Braidy និងចៅក្រមប្រធាន David Re។ ចាប់ពីខែមករា ឆ្នាំ២០១៤ រហូតដល់ខែកញ្ញា ឆ្នាំ២០១៩ អង្គជំនុំជម្រះសាលាដំបូង I ពិនិត្យមើលលើរឿងក្តីទីមួយ Ayyash និងអ្នកដទៃទៀត (STL-11-10)[218]។ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ មានការប្រកាសថារឿង ក្តីថ្មី ដែលមានពាក់ព័ន្ធជាមួយ Ayyash ផងដែរនោះ ត្រូវចូលដល់ដំណាក់កាលជំនុំជម្រះ[219]។

១០៩, នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ប្រធានអង្គជំនុំជម្រះតុលាការ កំពូលលោក Hrdličková បានចេញសេចក្តីសម្រេច ចាប់ផ្តើមជាផ្លូវការចំពោះអង្គជំនុំជម្រះសាលាដំបូងថ្មី (អង្គជំនុំជម្រះសាលាដំបូង II) ដើម្បីជំនុំជម្រះលើរឿងក្តី Ayyash ចុងក្រោយបំផុត (STL-18-10)[220]។ ចៅក្រម Nosworthy ចៅក្រម Braidy និង

---

[218] រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Ayyash និងអ្នកផ្សេងទៀត* (តុលាការពិសេសសម្រាប់ប្រទេសលីបង់) រឿងក្តីលេខ STL-11-01 <https://www.stl-tsl.org/en/the-cases/stl-11-01>។

[219] រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Ayyash* (តុលាការពិសេសសម្រាប់ប្រទេសលីបង់) រឿងក្តីលេខ STL-18-10 <https://www.stl-tsl.org/en/the-cases/stl-18-10>។

[220] លេខ STL-18-10/I/PRES រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash*, F0056, ដីកាចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៩។

ចៅក្រម Re មិនត្រូវបានតែងតាំងសម្រាប់អង្គជំនុំជម្រះសាលាដំបូងថ្មីនេះទេ ជំនួសវិញចៅក្រមបម្រុងពីររូប មកពីរឿងក្តី Ayyash ទីមួយ ត្រូវបានតែងតាំង រួមជាមួយចៅក្រមផ្សេងទៀតចំនួនបីរូប។

១១០, នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ ចៅក្រម Re ដែលមិនសប្បាយចិត្តបានដាក់សំណើជាមួយនឹងមន្ត្រីចុះបញ្ជីតុលាការ ស្នើសុំលុបចោលភ្លាមៗ និងប្រកាសថាមោឃៈ ចំពោះដីកាបង្គាប់របស់លោកស្រីប្រធាន ឱ្យចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូង ៕។ ចៅក្រម Re បានលើកទឡ្លីករណ៍ថា លោកស្រីប្រធាន Hrdličková បើតាមវិធាន ៣៧(ខ) នៃវិធានស្តីពីនីតិវិធី និងភស្តុតាង មិនបាន “ប្រឹក្សាជាមួយសមាជិកក្រុមប្រឹក្សា [ចៅក្រម] ដទៃទៀត ទៅលើបញ្ហាសំខាន់ៗទាំងអស់ ទាក់ទងនឹងការប្រព្រឹត្តិទៅនៃអង្គជំនុំជម្រះ”[221]។ ជាពិសេស លោកចៅក្រមបានលើកទឡ្លីករណ៍ថា “ការចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ គឺច្បាស់ណាស់ថាស្ថិតក្នុងនិទ្ទេសនៃ “បញ្ហា ចម្បងៗទាក់ទងនឹងការប្រព្រឹត្តិទៅនៃអង្គជំនុំជម្រះ”[222]។

---

[221] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Ayyash* លេខ STL-18-10/MISC.2/AC, F0001, បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ កថាខណ្ឌ ១៥។

[222] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Ayyash* លេខ STL-18-10/MISC.2/AC, F0001, បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៩ កថាខណ្ឌ ១៥។

១១១, នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ ចៅក្រម Re បានដាក់សំណើមួយទៀត ដោយលើកនេះបានលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះតុលា ការកំពូលមានយុត្តាធិការស្រាប់ក្នុងការបំពេញ “ការត្រួតពិនិត្យ តាមផ្លូវតុលាការ ទៅលើសេចក្តីសម្រេចរដ្ឋបាលដែលមានលក្ខ-ណៈប្រហែលតុលាការ (a quasi-judicial administrative decision)”[223]។ ចៅក្រម Re ក៏បានស្នើសុំផងដែរឱ្យដកលោក ប្រធាន Hrdličková ចេញពី “សមាជិកភាពនៃក្រុមប្រឹក្សាជំនុះជម្រះតុលាការកំពូល ដែលត្រូវធ្វើការសម្រេចលើបញ្ហានេះ”[224]។ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩ លោកស្រីប្រធានបានច្រានចោលសំណើសួរ ដោយមូលហេតុ “មិនអាចទទួលយកបាន និងគ្មានខ្លឹម សារ” ដោយលោកស្រីប្រធានបានសម្រេចថា “មិនមានបទប្បញ្ញត្តិណានៅក្នុងកិច្ចព្រមព្រៀងលក្ខន្តិក: ឬវិធាន បានប្រមើលមើលអំពីលទ្ធភាព ដែលមាន

[223] តុលាការ STL រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0001, បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ កថាខណ្ឌ ១។

[224] តុលាការ STL, រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0001, បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៩ កថាខណ្ឌ ៣។

តតិយជនមកជំទាស់ចំពោះដីកាសម្រេចរដ្ឋបាលរបស់ប្រធានអង្គជំនុំជម្រះឡើយ”[225]។

១១២, នៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ក្រុមប្រឹក្សាជំនុំជម្រះ ដែលមានចៅក្រមចំនួនបីរូប បានអនុញ្ញាតតាមសំណើរបស់លោកស្រីប្រធាន Hrdličková សុំដកខ្លួនចេញ[226]។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ អង្គជំនុំជម្រះតុលាការកំពូល ដែលមានចៅក្រមចំនួនបួនរូបបានពិភាក្សាសម្រេចលើសំណើរបស់ចៅក្រម Re ហើយបានចេញសេចក្តីសម្រេចខុសគ្នា ដោយសំឡេងស្មើ[227]។ ចៅក្រមពោក់ កណ្តាលបានសម្រេចថា អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការស្រាប់ហើយអនុញ្ញាតឱ្យបើកសវនាការបណ្តឹងសារទុក្ខ ចំណែកចៅក្រម

---

[225] តុលាការ STL រឿងក្តី *វរជ្ជអាយ៉ូ តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ “បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ” ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ៧។

[226] តុលាការ STL រឿងក្តី *វរជ្ជអាយ៉ូ តទល់នឹង Salim Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0003, អនុស្សរណរណៈផ្ទៃក្នុងរបស់ប្រធាន ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៩ កថាខណ្ឌ ២។ តុលាការ STL រឿងក្តី *វរជ្ជអាយ៉ូ តទល់នឹង Ayyash* លេខ STL-I8-I0/MISC.2/0TH/R25, F0005, សេចក្តីសម្រេចលើការដកខ្លួនរបស់ប្រធាន Hrdlickova ចុះថ្ងៃទី0៤ ខែធ្នូ ឆ្នាំ២០១៩។

[227] តុលាការ STL រឿងក្តី *វរជ្ជអាយ៉ូ តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ “បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ” ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩។

ពីររូបទៀតមិនយល់ស្រប[228]។ ដោយមិនមានយន្តការត្រឹមត្រូវ ដើម្បីដោះស្រាយភាពជាប់គាំងផ្នែកនីតិវិធី ទើបអង្គជំនុំជម្រះ តុលាការកំពូលសម្រេចថា ជីកាសម្រេចដែលរងការជំទាស់មាន អានុភាព ដោយគាំទ្រជីកាសម្រេចកន្លងមករបស់លោកស្រីប្រធាន Hrdličková ច្រានចោលការអះអាងរបស់ចៅក្រម Re កាលពី ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩[229]។ អង្គជំនុំជម្រះតុលាការ កំពូលបានសម្រេចថា "សំអាងហេតុដែលនាំទៅដល់លទ្ធផល នេះគឺ ការ ដែលម្ចាស់បណ្តឹងឧទ្ធរណ៍ មិនបានធ្វើឱ្យចៅក្រមភាគ ច្រើនលើសលប់តាមការតម្រូវ ជឿជាក់បានថា គួរតម្កល់បណ្តឹង ឧទ្ធរណ៍"[230]។

---

[228] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តី សម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១៣-១៥។

[229] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តី សម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ២៣-២៤។

[230] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តី សម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ២៣ (គូសបញ្ជាក់បន្ថែម)។

១១៣, ស្ថានភាពជាប់គាំងមានលក្ខណៈពិសេស។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា បន្ទាប់ពីការដកខ្លួនចេញរបស់លោកស្រីប្រធាននាពេលនេះអង្គជំនុំជម្រះ មានចៅក្រមតែបួនរូបប៉ុណ្ណោះ។ ដោយទទួលស្គាល់ស្ថានភាពនេះមិនល្អ ទើបអង្គជំនុំជម្រះកត់សម្គាល់ថា[231]

«មិនមានបទប្បញ្ញត្តិណានៅក្នុងលក្ខន្តិកៈដែលចែងថាចៅក្រមបម្រុងអាចអង្គុយនៅក្នុងអសនៈ អង្គជំនុំជម្រះតុលាការកំពូលឡើយ។ លើសពីនេះទៀត លក្ខន្តិកៈមិនបានចែងអំពីការតែងតាំងចៅក្រមពីអង្គជំនុំជម្រះផ្សេង មកបំពេញតួនាទីនៅអង្គជំនុំជម្រះតុលាការកំពូល ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ឡើយ (លុបចោលការដកស្រង់)។»

១១៤, អង្គជំនុំជម្រះកត់សម្គាល់ នៅកថាខណ្ឌ១៦ ថា[232]

---

[231] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១១។

[232] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១៦។

«លក្ខន្តិក:ក៏ដូចជាវិធាន មិនបានប្រមើលមើលដោយជាក់ច្បាស់អំពីកាល:ទេស: ដែលថៅក្រមនៃអង្គជំនុំជម្រះតុលាការកំពូល បានបែងចែកគ្នាយ៉ាងស្មើ លើបញ្ហាដែលតម្រូវឱ្យមានការសម្រេច ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍។ កាល:ទេស: បែបនេះ មិនអាចកើតមានឡើងចំពោះសមាសភាពទូទៅនៃអង្គជំនុំជម្រះតុលាការកំពូល ដែលមានថៅក្រមប្រាំរូបឡើយ។»

១១៥, អង្គជំនុំជម្រះកត់សម្គាល់បន្ថែមថា "វាហាក់ដូចជាថាអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការឬអង្គជំនុំជម្រះព្រហ្មទណ្ឌអន្តរជាតិដទៃទៀត មិនដែលជួបស្ថានភាពដែលបែងចែកគ្នាយ៉ាងស្មើលើបញ្ហាដែលប៉ះពាល់ដល់ការសម្រេចសេចក្តីលើបណ្តឹងឧទ្ធរណ៍ " (ដោយគូសបញ្ជាក់បន្ថែម)[233]។

១១៦, អង្គជំនុំជម្រះបានបន្តពិភាក្សាលើវិធីសាស្ត្រ ដែលតុលាការជាតិ និងអន្តរជាតិដទៃផ្សេងទៀត បានពឹងផ្អែកលើយន្តការផ្ទៃក្នុង ដើម្បីដោះស្រាយបញ្ហាអង្គជំនុំជម្រះ បែងចែកគ្នាយ៉ាងស្មើ។ អង្គជំនុំជម្រះបានកត់សម្គាល់ថា យុត្តាធិការជាច្រើនពឹងផ្អែកទៅលើសំឡេងឧត្តមានុភាព (ជាទូទៅជាសំឡេងឆ្នោតរបស់ថៅក្រមប្រធាន) ដើម្បីបំបែកភាពទាល់ច្រកផ្នែកតុលាការនេះ ឧទាហរណ៍តុលាការ

[233] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១៧ (គូសបញ្ជាក់បន្ថែម)។

យុត្តិធម៌អន្តរជាតិ the Assemblee Pleniere de la Cour de Cassation of Lebanon រួម ជា មួយ Conseil Constitutionnel របស់បារាំង[234]។ ប្រហែលគ្នានេះដែរ នៅតុលាការយុត្តិធម៌សហភាពអឺរ៉ុប នៅពេលចៅក្រមមានចំនួនគត់គូ ចៅក្រមដែលអតីត ភាពតិចជាងគេបំផុត ត្រូវបានតម្រូវឱ្យអវត្តមានពីការពិភាក្សាសម្រេច[235]។

១១៣, ក្នុងពេលជាមួយគ្នានេះ នៅ អូស្ត្រាលី នូវែលហ្សឺឡង់ រួមជាមួយនឹង សហរដ្ឋអាមេរិក ផងដែរ ច្បាប់បានចែងច្បាស់ថា ក្នុងករណីដែលមានការបែងចែកគ្នាយ៉ាងស្មើនៅតុលាការកំពូល ជីកាសម្រេច

---

[234] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១៨, ២០ ដកស្រង់ លីបង់ ច្បាប់ស្តីពី "ការរៀបចំតុលាការ (ក្រឹត្យច្បាប់ ១៥០ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៨៣ និងវិសោធនកម្ម) មាត្រា ៣០ (relatifa la composition et au vote del 'Assemblee Pleniere de la Cour de Cassation) ប្រទេសបារាំង រដ្ឋធម្មនុញ្ញ មាត្រា ៥៦។

[235] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ១៩ ដកស្រង់ តុលាការយុត្តិធម៌ វិធាននីតិវិធីរបស់តុលាការយុត្តិធម៌ មាត្រា ៣៣ លក្ខន្តិក:របស់តុលាការយុត្តិធម៌អន្តរជាតិ មាត្រា ៥៥(២)។

ដែលរងការជំទាស់ត្រូវមានអានុភាព[236]។ ចំណែកនៅ ចក្រភពអង់ គ្លេស តុលាការកំពូលដែលបែងចែកគ្នាយ៉ាងស្មើនឹងធ្វើឱ្យមានការ ជំនុំជម្រះជាថ្មីលើរឿងក្តីនៅក្នុងផ្នែកព្រហ្មទណ្ឌនៃតុលាការកំពូល[237]។

---

[236] តុលាការ STL រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ២៣ ដកស្រង់ ច្បាប់ស្តីពីតុលាការ ឆ្នាំ១៩០៣ (Cth) មាត្រា ២៣ ច្បាប់ស្តីពីតុលារការជាន់ខ្ពស់ ឆ្នាំ២០១៦ (NZ) s 85(2), សហរដ្ឋអាមេរិក តុលាការកំពូល រឿងក្តី *Durant តទល់នឹង Essex Company* លេខ 74 U.S. 107 ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៦៨។ សហរដ្ឋអាមេរិក តុលាការកំពូល រឿងក្តី *Neil តទល់នឹង Biggers* លេខ 409 U.S. 188 ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៧២ សហរដ្ឋអាមេរិក តុលាការកំពូល រឿងក្តី *Washington តទល់នឹង US*. លេខ 584, US ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨។ សហរដ្ឋអាមេរិក តុលាការកំពូល រឿងក្តី *Dollar General Corp. តទល់នឹង Mississippi Band of Choctaw Indians* ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ លេខ 579 US។

[237] តុលាការ STL, រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Samil Jamil Ayyash* លេខ STL-18-10/MISC.2/AC, F0006, សេចក្តីសម្រេចលើ "បណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចរបស់ប្រធានចាប់ផ្តើមអង្គជំនុំជម្រះសាលាដំបូងទីពីរ" ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ កថាខណ្ឌ ២០ ដកស្រង់ ច្បាប់ស្តីពីតុលាការកំពូល ឆ្នាំ១៩៨១ (UK) s 55(5)។

អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការពិសេសសម្រាប់ប្រទេសលីបង់ ញត្តិស្តីពី "យុត្តាធិការដែលមានស្រាប់"

១១៨, នៅក្នុងសេចក្តីសម្រេចកន្លងមកទាក់ទងនឹងរឿងក្តី El Sayed អង្គជំនុំជម្រះតុលាការកំពូល បានត្រួតពិនិត្យមើលលើសញ្ញាណ និង វិសាលភាពនៃយុត្តាធិការដែលមានស្រាប់។ កថាខណ្ឌខាងក្រោម ត្រូវបានថៅក្រម Re ពឹងផ្អែកលើ សម្រាប់សារណារបស់គាត់ ដែលថា អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការជំនុំជម្រះលើបញ្ហាទាក់ទងនឹងសេចក្តីសម្រេចរដ្ឋបាល។ នៅក្នុងរឿងក្តី El Sayed អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា[238]

«៤៥. ចំពោះតុលាការសម្រាប់ "យុត្តាធិការដែលមានស្រាប់" យើងចង់ថា សិទ្ធិអំណាចរបស់អង្គជំនុំជម្រះរបស់តុលាការ ក្នុងការសម្រេចលើបញ្ហាគតិយុត្តចៃដន្យដែលកើតឡើងជាលទ្ធផលផ្ទាល់នៃនីតិវិធីដែលតុលាការបានទទួលដោយសារមូលហេតុនៃបញ្ហាដែលស្ថិតក្រោមយុត្តាធិការចម្បងរបស់ខ្លួន។ យុត្តាធិការដែលមានស្រាប់នេះ កើតឡើងនៅខណៈពេលដែល បញ្ហាដែលតុលាការមានយុត្តាធិការចម្បង ត្រូវបាននាំយកមកជាក់នៅចំពោះមុខស្ថាប័នតុលាការ។ ជាពិសេស តុលាការអាចប្រើប្រាស់បាននៅពេលដែល

---

[238] តុលាការ STL ក្នុងរឿងក្តី *El Sayed* លេខ CH/PRES/2010/04 ជីកាបញ្ជូនរឿងទៅអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០ កថាខណ្ឌ ៤៥, ៤៨-៤៩។

តុលាការដទៃទៀត មិនមានសិទ្ធិអំណាចក្នុងការប្រកាសលើ បញ្ហាគតិយុត្តចែដទ្យនេះ ដោយសារតែការជាប់គាំងផ្នែក គតិយុត្ត ឬខុបសត្តជាក់ស្តែង។ ហេតុដូច្នេះ យុត្តាធិការដែល មានស្រាប់ គឺជាយុត្តាធិការបន្ទាប់បន្សំ ឬចែដទ្យ សម្រាប់ យុត្តាធិការចម្បង ហើយត្រូវបានចាត់ទុកថាចាំបាច់ ដោយសារ តែតម្រូវការបន្ទាន់ក្នុងការធានានូវរដ្ឋបាលតុលាការ ដែលល្អ និងប្រកបដោយយុត្តិធម៌ រួមទាំងការគោរពទាំងស្រុងចំពោះ សិទ្ធិមនុស្ស ដែលនៅជាធរមាន សម្រាប់រាល់អ្នកដែលពាក់ព័ន្ធ នៅក្នុងកិច្ចដំណើរការនីតិវិធីអន្តរជាតិ ដែលតុលាការនេះ មាន យុត្តាធិការជាក់ច្បាស់។»

...

៤៨. ការអនុវត្តរបស់ស្ថាប័នតុលាការអន្តរជាតិ បង្ហាញថា វិធានដែលកំណត់លើតុលាការអន្តរជាតិ នូវយុត្តាធិការដែល មានស្រាប់ មានគោលដៅទូទៅដើម្បី ជួសជុលភាពខ្វះ ចន្លោះ ដែលអាចកើតមាន ក្នុងបទប្បញ្ញត្តិគតិយុត្ត នៃកិច្ចដំណើរការ នីតិវិធី។ ពិសេសជាងនេះទៀតនោះ វាបម្រើដល់គោលបំណង មួយ ឬច្រើនដូចតទៅ (១) ធានានូវរដ្ឋបាលតុលាការដោយ យុត្តិធម៌ (២) គ្រប់គ្រងលើដំណើរការ និងការប្រព្រឹត្តទៅដោយ ត្រឹមត្រូវនូវកិច្ចដំណើរការនីតិវិធី (៣) ការពារនិងធានាការ ប្រតិបត្តិនូវមុខងារតុលាការ ដោយតុលាការ(ជាឧទាហរណ៍ការ ដោះស្រាយការប្រមាថតុលាការ)។ យុត្តាធិការដែលមានស្រាប់

អាចប្រើប្រាស់តែត្រឹមកម្រិតដែល ធ្វើឱ្យមានការអនុវត្តដោយ ពេញលេញនូវយុត្តាធិការចម្បងរបស់តុលាការតែប៉ុណ្ណោះ (ដូច ជាក្នុងករណីជាមួយcompetence de la competence) ឬសិទ្ធិអំណាចរបស់តុលាការទៅលើបញ្ហាណាមួយដែលជា បញ្ហាចែដន្យសម្រាប់យុត្តាធិការចម្បងរបស់ខ្លួននិងការសម្រេច ដែលបម្រើដល់ផលប្រយោជន៍យុត្តិធម៌។

៤៩. ក៏ប៉ុន្តែយុត្តាធិការដែលមានស្រាប់ ជាកម្មវត្ថុនៃការ កម្រិតកំណត់។ យុត្តាធិការនេះចាំបាច់ត្រូវតែអនុលោមជាមួយ នឹងគោលការណ៍រដ្ឋបាលតុលាការដែលយុត្តិធម៌ និងការគោរព ពេញលេញចំពោះសិទ្ធិមនុស្ស និងនៅក្នុងវិស័យដោះស្រាយ តាមផ្លូវតុលាការ ចំពោះជម្លោះរវាងរដ្ឋ ដោយមានការយល់ព្រម ឬចេតនារបស់រដ្ឋពាក់ព័ន្ធ។ នេះមានន័យថា កិច្ចដំណើរការនីតិ វិធីព្រហ្មទណ្ឌអន្តរជាតិ ដែលយុត្តាធិការដែលមានស្រាប់ អាច មិនត្រូវបានប្រើប្រាស់ ក្នុងលក្ខណៈដែលស៊ីសង្វាក់ជាមួយ សិទ្ធិ ជាសារវ័ន្តរបស់ជនជាប់ចោទ ឬបុគ្គលដទៃទៀត ដែលចូលរួម ពាក់ព័ន្ធ ក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ។ (លុបចោលការ ដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)។»

តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន

១១៩, ជាការគួរឱ្យចាប់អារម្មណ៍ អង្គជំនុំជម្រះតុលាការកំពូល នៅក្នុង សាលដីកាខាងលើ មិនបានលើកឡើងអំពីយន្តការ ដែលមាននៅ

ក្នុងវិធាននិង នីតិវិធីនៃតុលាការពិសេសសេសសល់ សម្រាប់ប្រទេសសេរ៉ាឡេអូន។ វិធាន១៦(ខ)(២) ចែងថា[239]

«ខ. ទោះជាដោយសារមូលហេតុអ្វីក្តី ប្រសិនបើថៅក្រមមិនអាចបន្ត នៅក្នុងកិច្ចដំណើរការនីតិវិធី ការជំនុំជម្រះ ឬបណ្តឹងសាទុក្ខ ដែលត្រូវដំណើរការសវនាការដោយផ្នែកក្នុងអំឡុងរយៈពេល ដែលប្រហែលជាច្រើនជាងប្រាំថ្ងៃនោះថៅក្រមប្រធានអាចចាត់តាំងថៅក្រមផ្សេងទៀតចេញពីបញ្ជីថៅក្រម។

ប្រសិនបើមិនអាចស្វែងរកថៅក្រមជំទៃទៀតពីបញ្ជីថៅក្រមបាន ហើយថៅក្រមដែលនៅក្នុងក្រុមប្រឹក្សាយល់ស្របថាមិនប៉ះពាល់ដល់សេចក្តីសម្រេចទេនោះ ថៅក្រមដែលនៅមានវត្តមាន អាចបន្តដោយមិនមានវត្តមានថៅក្រមរូបនោះ។ ក្នុងករណីដែលអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល បន្តដំណើរការដោយមិនមានថៅ ក្រមមួយរូបក្នុងករណីដែលសេចក្តីសម្រេចនោះ បានបែងចែកគ្នាដោយស្មើ ចាំបាច់ត្រូវចេញដីកាបង្គាប់ឱ្យមាន កិច្ចដំណើរការនីតិវិធីការជំនុំជម្រះឬបណ្តឹងសាទុក្ខថ្មី។»

---

[239] តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន វិធាននីតិវិធី និងភស្តុតាង (វិសោធនកម្ម ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨) (អនុម័តថ្ងៃទី១៦ ខែមករា ឆ្នាំ២០០២) r 16(B)(ii)។

១២០, មិនធ្លាប់មានករណីដែលវិធាន ១៦(ខ)(២) ត្រូវបានយកមកប្រើប្រាស់ដោយជោគជ័យនោះឡើយ។

ករណីនៃការជាប់គាំងតុលាការនៅតុលាការ Nuremberg

១២១, ដូចដែលបានបញ្ជាក់ខាងលើ ការជាប់គាំងតុលាការគឺជាករណីកម្រ ហើយកាន់តែកម្រនៅក្នុងរឿងក្តីព្រហ្មទណ្ឌ។ ករណីតែមួយគត់នៃការជាប់គាំងតុលាការនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ក្រៅពី អ.វ.ត.ក) បានកើតឡើងនៅតុលាការ Nuremberg។ នៅក្នុងរឿងក្តីប្រឆាំងនឹង Franz von Papen អង្គជំនុំជម្រះដែលមានក្រុមប្រឹក្សាជំនុំជម្រះបួនរូប បានខ្វែងគំនិតគ្នាក្នុងចំនួនស្មើគ្នា ដោយចៅក្រមអាមេរិក និងចៅក្រមអង់គ្លេស បោះឆ្នោតឱ្យលើកលែងចោទប្រកាន់ ចំណែកចៅក្រមរុស្ស៊ី និងចៅក្រមបារាំងបោះ ឆ្នោតឱ្យដាក់ពិរុទ្ធភាព។ ដោយ មិនមានខាងណាមួយមានចេតនាចង់សម្របសម្រួល ទើបការបោះឆ្នោតដែលបណ្តាលឱ្យជាប់គាំងនេះធ្វើឱ្យមានការលើកលែងចោទប្រកាន់ដោយស្វ័យប្រវត្តិ។ លទ្ធ ផលប្រហែលគ្នាត្រូវបានធ្វើឡើងចំពោះជនជាប់ចោទ Hjalmar Schacht។

១២២, ធម្មនុញ្ញនៃតុលាការ Nuremberg បានចែងថា “តុលាការត្រូវមានសមាជិកបួនរូប”[240]។ ធម្មនុញ្ញបានចែងពីយន្តការ ដើម្បីដោះ

[240] ធម្មនុញ្ញតុលាការយោធាអន្តរជាតិ - ឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងស្តីពីការកាត់សេចក្តីនិងផ្តន្ទាទោសមហាឧក្រិដ្ឋជនសង្គ្រាមនៃប្រទេសកាន់អំណាចសម្ព័ន្ធមិត្តអឺរ៉ុប

ស្រាយភាពជាប់គាំងផ្នែកនីតិវិធី គឺសំឡេងឧត្តមានុភាព “តុលាការត្រូវចេញសេចក្តីសម្រេច ដោយសំឡេងភាគច្រើនលើសលប់ ក្នុងករណីដែលសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាព”[241]។ ទោះជាយ៉ាងនេះក្តី ធម្មនុញ្ញបានបញ្ជាក់ច្បាស់ថា រាល់ការ “កំណត់ពិរុទ្ធភាព និងការផ្តន្ទាទោស ត្រូវតែធ្វើឡើងដោយសំឡេងគាំទ្រ យ៉ាងហោចណាស់សមាជិកបីរូប នៃតុលាការ”[242]។ ម្យ៉ាងទៀត ប្រសិនបើសំឡេងឆ្នោតសម្រាប់ការកំណត់ពិរុទ្ធភាព ឬការលើកលែងចោទប្រកាន់ បានខ្វែងគ្នាដោយស្មើគ្នា ត្រូវផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ ដែលជាលទ្ធផលគឺលើកលែងការចោទប្រកាន់។

ខ. ការបិទបញ្ចប់ ឬការផ្អាកជាអចិន្ត្រៃយ៍ ចំពោះកិច្ចដំណើរការនីតិវិធី ដោយសារតែភាពមិនច្បាស់ប្រជាផ្នែកនីតិវិធី

១២៣, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ រួមជាមួយអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY និងអង្គបុរេជំនុំជម្រះនៃ អ.វ.ត.ក បានសម្រេចថា ក្នុងកាលៈទេសៈដែលមានការរំលោភបំពានខុសប្រក្រតីទៅលើសិទ្ធិរបស់ជនជាប់ចោទ

(“កិច្ចព្រមព្រៀងទីក្រុងឡុងដ៍”) (ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ១៩៤៥) *(“ធម្មនុញ្ញតុលាការ Nuremberg”)* មាត្រា ២ (គួសបញ្ជាក់បន្ថែម)។

[241] *ធម្មនុញ្ញតុលាការ Nuremberg មាត្រា ៤(ក)* (គួសបញ្ជាក់បន្ថែម)។

[242] *ធម្មនុញ្ញតុលាការ Nuremberg មាត្រា ៤(ក)* (គួសបញ្ជាក់បន្ថែម)។

ឧបាស្រ័យដែលសមស្របគឺផ្អាកជាអចិន្ត្រៃយ៍ ឬបិទបញ្ចប់កិច្ច
ដំណើរការនីតិវិធី ដែលហៅថា ទ្រឹស្តីនៃការរំលោភបំពាន។

១២៤, នៅក្នុងរឿងក្តី Lubanga អង្គជំនុំជម្រះតុលាការកំពូលបានសម្រេច
ថា[243]

*«ការផ្អាកកិច្ចដំណើរការនីតិវិធីគឺជាឧបាស្រ័យខ្លាំងក្លា។ នេះ
នាំឱ្យមានការផ្អាកកិច្ចដំណើរការនីតិវិធី ហើយប្រហែលជា
ប៉ះពាល់ខ្លាំងដល់គោលដៅនៃការជំនុំជម្រះ គឺការផ្តល់យុត្តិធម៌
ក្នុងរឿងក្តីជាក់លាក់ ព្រមទាំងប៉ះពាល់ដល់គោលបំណងធំ
ដែលមានចែងក្នុងបុព្វកថានៃលក្ខន្តិក:ទីក្រុងរ៉ូម។ នេះជាឧបា-
ស្រ័យពិសេស។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា
"ក្នុងករណីដែលការជំនុំជម្រះប្រកបដោយយុត្តិ-ធម៌ មិនអាច
ធ្វើទៅបាន ដោយសារតែ ការរំលោភបំពានទៅលើសិទ្ធិជាសារ
វ័ន្តរបស់ជនសង្ស័យ ឬជនជាប់ចោទ ដោយអ្នកចោទប្រកាន់ពួក
គេ គឺផ្ទុយនឹងលក្ខខណ្ឌ ដែលត្រូវនាំយកបុគ្គលនោះមកជំនុំ
ជម្រះ [...] ប្រសិនបើមិនអាចមានការជំនុំជម្រះប្រកបដោយ*

---

[243] សាលដីកាលើបណ្តឹងសាទុក្ខរបស់រដ្ឋអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់ អង្គជំនុំ
ជម្រះសាលាដំបូងទីមួយ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១០ មានចំណងជើងថា
"សេចក្តីសម្រេចលើសំណើបន្ទាន់របស់រដ្ឋអាជ្ញាសុំផ្លាស់ប្តូរពេលវេលាកំណត់សម្រាប់
បង្ហាញអត្តសញ្ញាណអន្តរការី ១៤៣ ឬជាជម្រើសម្យ៉ាង ទៀត សុំផ្អាកកិច្ចដំណើរ
ការនីតិវិធី (តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះតុលាការកំពូល រឿងក្តីលេខ
ICC-01/04-01/06-2582 ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០) កថាខណ្ឌ ៥៥។

យុត្តិធម៌បាន គោលដៅនៃដំណើរការតុលាការ គឺត្រូវរងផលប៉ះពាល់ ហើយចាំបាច់ត្រូវបញ្ឈប់ដំណើរការ"។(លុបចោលការដកស្រង់)(ដោយគូសបញ្ជាក់បន្ថែម)។»

១២៥, ក្នុងការសម្រេចថាតើកាលៈទេសៈតម្រូវ ឱ្យផ្អាកកិច្ចដំណើរការនីតិវិធីនោះដែរឬទេ អង្គជំនុំជម្រះសាលាដំបូង ក្នុងរឿងក្តី បានគាំទ្រសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល (ខាងលើ) ហើយសម្រេចថា មានសំណួរដែលនៅជាប់ពាក់ព័ន្ធចំនួនពីរទៀតដែលត្រូវចោទឡើយ[244]

«ហេតុដូច្នេះ អង្គជំនុំជម្រះ នៅក្នុងបរិបទនេះចាំបាច់ត្រូវចោទសួរសំណួរចំនួនពីរដូចតទៅ ទីមួយ តើជារឿង "គួរឱ្យស្អប់ខ្ពើម" ឬ "មិនគួរឱ្យពេញចិត្ត" ដែរឬទេ សម្រាប់រដ្ឋបាលតុលាការ ដែលអនុញ្ញាតឱ្យកិច្ចដំណើរការនីតិវិធីបន្តទៅមុខទៀត? ឬទីពីរ តើសិទ្ធិរបស់ជនជាប់ចោទ ត្រូវបានរំលោភបំពានដល់កម្រិតមួយដែលការជំនុំជម្រះប្រកបដោយយុត្តិធម៌ មិនអាចធ្វើទៅរួចទេ?(លុបចោលការដកស្រង់)(ដោយគូសបញ្ជាក់បន្ថែម)។»

---

[244] សេចក្តីសម្រេចកោសលុបលើ "ពាក្យសុំរបស់មេធាវីការពារក្តីស្វែងរកការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍" (តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងទីមួយ រឿងក្តីលេខ ICC-01/04-01/06-2690 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១) កថាខណ្ឌ ១៦៦។

១២៦, អង្គជំនុំជម្រះសាលាដំបូងក៏បានកត់សម្គាល់ផងដែរថា វិធានការសំខាន់នៃការផ្អាកកិច្ចដំណើរការនីតិវិធីគួរត្រូវបានប្រើប្រាស់ម្តងម្កាលប៉ុណ្ណោះ ដោយអង្គជំនុំជម្រះសម្រេចថា[245]

«ដោយផ្អែកលើយុត្តិសាស្ត្រ ដែលត្រូវបានសង្ខេបខាងលើ ឧបាស្រ័យសំខាន់យ៉ាងប្រាកដនេះ គួរត្រូវបានរក្សាទុកយ៉ាងម៉ឺងម៉ាត់ សម្រាប់តែករណីណាដែលតម្រូវចាំបាច់ ដោយផ្អែកលើការវិភាគយ៉ាងប្រុងប្រយ័ត្ន ក្នុងការចាត់វិធានការពិសេសនិងធ្ងន់ធ្ងរបំផុត ដើម្បីបិទបញ្ចប់កិច្ចដំណើរការនីតិវិធី (ដែលផ្ទុយពីការអនុម័តយកឧបាស្រ័យដែលធូរស្រាលជាងមួយចំនួន)។ (ដោយគូសបញ្ជាក់បន្ថែម)។»

១២៧, ចំពោះបញ្ហាថាតើអ្វីជាការប្រមាថ “មិនគួរឱ្យពេញចិត្ត” ឬ “គួរឱ្យស្អប់ខ្ពើម” ចំពោះរដ្ឋបាលតុលាការនោះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់លក្ខណវិនិច្ឆ័យយ៉ាងខ្ពស់ ដោយអង្គជំនុំជម្រះលើកឡើងថា[246]

---

[245] សេចក្តីសម្រេចកោសលុបលើ “ពាក្យសុំរបស់មេធាវីការពារក្តីស្វែងរកការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍” (តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះសាលាដំបូងទីមួយ រឿងក្តីលេខ ICC-01/04-01/06-2690 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១) កថាខណ្ឌ ១៦៨។

[246] សេចក្តីសម្រេចកោសលុបលើ “ពាក្យសុំរបស់មេធាវីការពារក្តីស្វែងរកការផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍” (តុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះ

«ឧទាហរណ៍ឃើងច្បាស់អំពីស្ថានភាព ដែលអាចមានការចាំបាច់សម្រាប់ការផ្តាក រួមមានការប្រព្រឹត្តិដោយមិនត្រឹមត្រូវជាសំខាន់ទៅលើជនជាប់ចោទដើម្បីទទួលបានភស្តុតាង (ដូចជា ការប្រើប្រាស់ទារុណកម្ម) ឬ ការលាក់បាំងភស្តុតាងដោះបន្ទុកសំខាន់។»

១២៨, នៅក្នុងរឿងក្តី Nikolic អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានកត់សម្គាល់ពីលក្ខណៈនិច្ឆ័យខ្ពស់ (ខ្លាំង) ដែលតម្រូវឱ្យមាន មុនពេលដែលជនត្រូវចោទ អាចប្រើប្រាស់ទ្រឹស្តីការរំលោភបំពាន (ក្រោយមកត្រូវបានគាំទ្រដោយអង្គជំនុំជម្រះតុលាការកំពូល) ដោយអង្គជំនុំជម្រះសាលាដំបូងសម្រេចថា[247]

«នៅក្នុងស្ថានភាពដែលជនជាប់ចោទ ត្រូវបានធ្វើបាបយ៉ាងធ្ងន់ធ្ងរបំផុត ដែលអាចត្រូវទទួលរងទារុណកម្ម ឬប្រព្រឹត្តិកម្មអមនុស្សធម៌ សាហាវឃោរឃៅ ឬបន្ទាបបន្ថោកមុន

សាលាដំបូងទីមួយ រឿងក្តីលេខ ICC-01/04-01/06-2690 ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១១) កថាខណ្ឌ ១៩៧។

[247] តុលាការ ICTY សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីជំទាស់ នឹងការអនុវត្តយុត្តាធិការដោយតុលាការ រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Nikolic* (លេខ IT-94-2-PT) ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០២ កថាខណ្ឌ ១១៤។ ដូចបានបញ្ជាក់នៅក្នុងតុលាការ ICTY សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ បន្ទាន់បង្ខំទាក់ទងនឹងនីត្យានុកូលភាពនៃការចាប់ខ្លួន រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Nikolic* (IT-94-2-AR73) ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០០៣ កថាខណ្ឌ ៣១។

ពេលប្រគល់មកអង្គជំនុំជម្រះនោះ ចំណុចនេះអាចបង្កើតបាន ជាឧបសគ្គផ្នែកគតិយុត្ត ចំពោះការប្រើប្រាស់យុត្តាធិ ការទៅលើជនជាប់ចោទបែបនោះ។ (ដោយគូសបញ្ជាក់ បន្ថែម)។»

១២៩, អង្គបុរេជំនុំជម្រះរបស់ អ.វ.ត.ក បានគាំទ្រការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងរឿងក្តី Lubanga ដោយបញ្ជាក់ថា[248]

«នៅទីបំផុត អំណាចព្យួរកិច្ចស៊ើបសួរ គឺជាអំណាចឆន្ទានុសិទ្ធិ ដែលពាក់ព័ន្ធទៅនឹងការវាយតម្លៃរបស់តុលាការថា តើការបំពានលើសិទ្ធិរបស់ជនត្រូវចោទ ឬជនជាប់ចោទនោះ មានលក្ខណៈធ្ងន់ធ្ងរដែលទាំឱ្យរាំងស្ទះការអនុវត្តយុត្តាធិការដែរឬទេ?

... ផ្អែកតាមការពិចារណាខាងលើនេះ អង្គបុរេជំនុំជម្រះនឹងត្រូវពិចារណាថាតើមានការបំពានធ្ងន់ធ្ងរ ឬការរំលោភជាក់ស្តែងលើសិទ្ធិរបស់ ដើមបណ្តឹងឧទ្ធរណ៍ដែរឬទេ។ ត្រូវតែមានភស្តុតាងធ្វើឱ្យអង្គបុរេជំនុំជម្រះជឿជាក់ថា កំហុសឆ្គងដែលរងការចោទប្រកាន់នោះ ពិតជាកើតចេញពីការរំលោភសិទ្ធិរបស់ជនត្រូវចោទ ក្នុងការទទួលបានការជំនុំជម្រះប្រកបដោយ

[248] សំណុំរឿង ០០២ ឯកសារ D264/2/6 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួដោយមូលហេតុរំលោភនីតិវិធី D264/1 ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ទំព័រ ១៥-១៦ កថាខណ្ឌ ២៦។

យុត្តិធម៌ ហើយការរំលោភបំពាននេះ មានលក្ខណៈធ្ងន់ធ្ងរទើប អង្គបុរេជំនុំជម្រះអាចសម្រេចព្យួរកិច្ចស៊ើបសួរជាអចិន្ត្រៃយ៍ បាន (លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)។»

១៣០, អង្គបុរេជំនុំជម្រះបានកត់សម្គាល់បន្ថែមថា[249]

«តាម ព្យួរនីតិវិធី (ដែលជាវិធានការចុងក្រោយ) ដែលត្រូវយកមកអនុវត្ត តែក្នុងករណីពិសេសនិងករណីមានការរំលោភធ្ងន់ធ្ងរលើសិទ្ធិរបស់ជនត្រូវចោទ ដែលមិនអាចជួសជុលបាន ឬ បំពានទៅលើស្មារតីយុត្តិធម៌របស់តុលាការតែប៉ុណ្ណោះ។ មានតែករណីពិសេសដែលការបំពានមានលក្ខណៈធ្ងន់ធ្ងរទេ ទើបតុលាការអាចចាត់ទុកថា ដំណោះស្រាយនេះត្រឹមត្រូវនេះជាមូលហេតុដែលតម្រូវឱ្យយកបទដ្ឋានយ៉ាងខ្ពស់មកប្រើ ដើម្បីកំណត់ថា មានឬគ្មានការរំលោភបំពាននិងដើម្បីកំណត់ថាតើការបំពាននោះ ធ្ងន់ធ្ងរគ្រប់គ្រាន់ដែលតម្រូវឱ្យប្រើដំណោះស្រាយនេះដែរឬទេ។ (លុបចោលការដកស្រង់) (ដោយគូសបញ្ជាក់បន្ថែម)។»

[249] សំណុំរឿង ០០២ ឯកសារ D264/2/6 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួដោយមូលហេតុរំលោភនីតិវិធី D264/1 ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ ទំព័រ ១៧-១៨ កថាខណ្ឌ ២៨។

RAOUL
WALLENBERG
INSTITUTE
OF HUMAN RIGHTS AND HUMANITARIAN LAW

ស៊ុយអែត
Sverige